សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ម៉ក់ ធឿន**
**ក.អ៊ុំ ពេជ្រសូនីកា**

សាស្ត្រាចារ្យណែនាំ
លោក **ខាត់ ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២១

ឆ្នាំចូលរៀន ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ម៉ក់ ឡឿន** និង **អុំ ពេជ្រសុនីតា** ជានិស្សិតបរិញ្ញាបត្រឆ្នាំទី៤ ជំនាន់ទី ២១ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានសិក្សាចាប់ពីឆ្នាំ ២០១៧ ដល់ ២០២១។

**សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖**

- លោកឪពុក **អុំ សុភាំ** អ្នកម្តាយ **ឆេង សុខណៃ** និង លោកឪពុក **ម៉ក់ ហួយ** អ្នកម្តាយ **ជា ស្រីណាត** ដែលលោកពិតជាមានគុណដ៏ធំធេង ដែលលោកមិនត្រឹមតែផ្តល់កំណើតដល់រូបយើងខ្ញុំប៉ុណ្ណោះទេ លោកបានខិតខំថែរក្សា ចិញ្ចឹមបីបាច់ ផ្តល់ដំបូន្មានល្អៗ ព្រមទាំង ខំប្រឹងប្រែងអស់ពីកំលាំងកាយចិត្ត លះបង់គ្រប់បែបយ៉ាងដើម្បីឲ្យកូនក្លាយជាអ្នកមានចំណេះដឹងមួយរូបនៅក្នុងសង្គម ។ លោកពិតជាបានជួបនូវឧបសគ្គការលំបាកជាច្រើន ប៉ុន្តែលោកមិនដែលត្អូញត្អែរ និងរុញរាឡើយ។ ដោយសារតែទទួលបានការលើកទឹកចិត្ត និងភាពកក់ក្តៅរបស់លោកទាំងពីរ ដែលជាកំលាំងចលករមួយដ៏មហិមាទើបយើងខ្ញុំក្លាយជានិស្សិតមួយរូបដែលបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ព្រមទាំងមានលទ្ធភាពក្នុងការសរសេរសារណាមួយនេះបាន។
- **រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា** និង **ក្រសួងអប់រំយុវជន និងកីឡា** ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការលើកកម្ពស់ទៅលើវិស័យអប់រំ ហើយបានបង្កើតនៅគ្រឹះស្ថានឧត្តមសិក្សាសម្រាប់បណ្តុះបណ្តាលចំណេះដឹងជាច្រើនដែលធ្វើឲ្យយុវជនជំនាន់ក្រោយ អាចបន្តការសិក្សា និងក្រេបជញ្ជក់យកចំណេះវិជ្ជាសម្រាប់ជួយខ្លួនពួកគេនៅពេលបច្ចុប្បន្ន និងអនាគត ។ ជាពិសេសគឺដើម្បីកសាងជាតិមាតុភូមិឲ្យមានការរីកចម្រើនជានិរន្តរ៍។
- **ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រីសាស្ត្រាចារ្យ** ដែលបានខិតខំអស់ពីកំលាំងកាយចិត្តពីសមត្ថភាពក្នុងការដឹកនាំគ្រប់គ្រង និងបង្ហាត់បង្រៀនរូបយើងខ្ញុំឲ្យទទួលបានចំណេះដឹងដើម្បីសរសេរសារណានេះឡើង ។
- លោកសាស្ត្រាចារ្យ **ខាត់ ធី** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ ណែនាំបង្ហាត់បង្ហាញពន្យល់ កែតម្រូវ និងបានបង្កលក្ខណៈងាយស្រួលដល់ការសរសេរសារណានេះឡើង។

ជាចុងក្រោយ យើងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តសិទ្ធិទាំងពួងលើលោកនេះឲ្យជួយតាមថែរក្សាអស់លោកអ្នកមានគុណ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ បងប្អូន រាមច្បង និងមិត្តភក្កិទាំងឡាយឲ្យជួបតែសេចក្តីសុខ សេចក្តីចម្រើនគ្រប់វេលាកុំបីឃ្លាងឃ្លាតឡើយ ។

# អារម្ភកថា

ជាបឋម ខ្ញុំបាទឈ្មោះ **ម៉ក់ ឌឿន** និង នាងខ្ញុំ **អ៊ុំ ពេជ្រសុនីតា** សូមស្វាគមន៍ដល់មិត្តអ្នកអានគ្រប់រូបជាពិសេស សិស្ស និស្សិត ជាទីរាប់អាន ព្រមទាំងសាស្ត្រាចារ្យជាទីគោរព ។

ក្នុងនាមជានិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច បានរៀបចំនូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ក្រោមប្រធានបទ ស្តីពី នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលត្រូវបានផ្តួចផ្តើមឡើងដោយយើងខ្ញុំទាំងពីរនាក់ និងមានការលើកទឹកចិត្តយ៉ាងពេញទំហឹងពីសំណាក់ លោកសាស្ត្រាចារ្យ **ខាត់ ធី** ដែលជាសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាការសម្រេចចិត្តរបស់យើងខ្ញុំទាំងពីរនាក់ ។

យើងខ្ញុំទាំងពីរបានសម្រេចជ្រើសរើសប្រធានបទនេះមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងឡើងក្នុងគោលបំណង ដើម្បីប្រមូលធាតុចូលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្នុងការចូលរួមជាវិភាគទានដ៏សំខាន់នៅក្នុងដំណើរនៃនីតិវិធីនៃការជម្រះក្តីលើកទី១ និងក៏ជាទុកសម្រាប់ឯកសារសម្រាប់ការបំពេញបន្ថែមនៃតម្រូវការរបស់មិត្តអ្នកអាន ក្នុងការសិក្សាស្រាវជ្រាវបន្ត ។ ជាពិសេសទៀតនោះ យើងខ្ញុំទាំងពីរក៏ចង់ដឹង និងចង់សិក្សាឲ្យបានស៊ីជម្រៅបន្ថែមទៀត អំពីខ្លឹមសារ និង អត្ថន័យ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល រួមទាំងការអនុវត្តជាក់ស្តែងនៃក្បួននីតិវិធីទាក់ទងនិងប្រធានបទនៃសាណានេះផងដែរ ។

យើងខ្ញុំ សង្ឃឹមថាកិច្ចការស្រាវជ្រាវមួយនេះ នឹងអាចក្លាយជាឯកសារមួយសម្រាប់ស្រាវជ្រាវ ជួយបំពេញបន្ថែមទៅតាមតម្រូវការសិក្សាផ្នែកទ្រឹស្តីច្បាប់ ។

មួយវិញទៀត យើងខ្ញុំទាំងពីរនាក់ ជានិស្សិតកំពុងសិក្សានៅឡើយ រីឯចំណេះដឹងនៅមានកម្រិតក្នុងការស្រាវជ្រាវ និង ចងក្រងឯកសារនេះឡើង ប្រាកដជាមាននូវចំណុចខ្វះខាតផ្នែកខ្លឹមសារ និងកំហុសឆ្គងខាងអក្ខរាវិរុទ្ធជាក់ជាមិនខាន ។ ដូច្នេះយើងខ្ញុំសង្ឃឹមថា រាល់កំហុសឆ្គងទាំងឡាយណាដែលកើតមានឡើងក្នុងប្រធានបទសារណានេះ នឹងទទួលបានការអធ្យាស្រ័យ ពីលោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានគ្រប់មជ្ឈដ្ឋានទាំងអស់ជាក់មិនខាន ។

យើងខ្ញុំ រងចាំនូវការរិះគន់ និងកែតម្រូវ ក្នុងន័យស្ថាបនា ពីសំណាក់អស់លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់គ្រប់ពេលវេលា ។

ជាទីបញ្ចប់នេះយើងខ្ញុំទាំងពីរនាក់ សូមជូនពរដល់ លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានគ្រប់រូបឲ្យជួបប្រទះតែពុទ្ធពរបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**....01

**ជំពូកទី១**

**សញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**១.១.គោលការណ៍នានានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**.... ០៣

១.១.១ គោលការណ៍ចំពោះមុខ.... ០៣

១.១.២ គោលការណ៍ជាអសាធារណៈ....០៤

១.១.៣ គោលការណ៍តុលាការអកម្ម....០៤

**១.២.ភាពចាំបាច់នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**....០៥

១.២.១ គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល....០៥

១.២.២ ការដាក់ឯកសារត្រៀម....០៦

១.២.៣ ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល.... ០៧

១.២.៤ កោះហៅគូភាគី ដើម្បីចូលរួមក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល.... ០៧

**ជំពូកទី២**

**នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**២.១.សកម្មភាព តុលាការ និង ភាគី នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**....០៩

**២.១.១.សកម្មភាពរបស់តុលាការ**....០៩

២.១.១.១ ការផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល....០៩

២.១.១.២.ការដឹកនាំ និងការរៀបចំការអះអាងរបស់ភាគី....១០

២.១.១.៣.ការកំណត់ចំណុចវិវាទ....១១

២.១.១.៤.ការរៀបចំភស្តុតាងទាក់ទងនិងចំណុចវិវាទ....១២

២.១.១.៥.ការបំបែក ឬ ការបញ្ចូលរឿងក្តី.... ១៣

**២.១.២.សកម្មភាពរបស់ភាគី**.... ១៤

២.១.២.១ ការដាក់មធ្យោបាយតទល់ ឬការពារខ្លួន....១៤

២.១.២.២ ការសុំបញ្ចូលបន្ថែម ឬ ផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង....១៤

២.១.២.៣ ការធ្វើបណ្តឹងតប....១៥

២.១.២.៤ ការស្នើសុំឱ្យភាគីម្ខាងទៀតដាក់ឯកសារ....១៥

២.១.២.៥ ការស្នើសុំឱ្យតុលាការពិនិត្យភស្តុតាង....................................................................១៥
**២.១.៣ សកម្មភាពរបស់ក្រឡាបញ្ជី**....................................................................................១៦
២.១.៣.១ ការធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល......................... ១៧
២.១.៣.២ កិច្ចការបញ្ជូននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល............................ ១៧
**២.២ ការសម្រេច និងបណ្តឹងឧបាស្រ័យ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**.... ១៨
**២.២.១ ការសម្រេចរបស់តុលាការ**...............................................................................១៩
២.២.១.១. ដីកាសម្រេច...........................................................................................១៩
២.២.១.២.អានុភាពនៃដីកាសម្រេច................................................................................២០
២.២.១.៣ ការផ្ទេរសមត្ថកិច្ចតុលាការ ..........................................................................២១
២.២.១.៤.ការដកហូតសមត្ថកិច្ចជំនុំជម្រះ ......................................................................២២
**២.២.២ ការប្តឹងឧបាស្រ័យ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**.............២២
២.២.២.១ ការប្តឹងតវ៉ាចំពោះការដឹកនាំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល.......................២៣
២.២.២.២ ប្តឹងតវ៉ាចំពោះកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល.................២៣
២.២.២.៣ ការប្តឹងដិតចិត្ត ..........................................................................................២៤
២.២.២.៤ ការប្តឹងជំទាស់ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល....................................២៤

## ជំពូកទី៣

## ការបញ្ចប់ និងអានុភាពនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

**៣.១.ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**.........................................២៦
៣.១.១.ការបញ្ចប់អំពីអង្គហេតុដែលត្រូវធ្វើការបញ្ជាក់ ........................................................២៦
៣.១.២.ការកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ....................................២៦
**៣.២.អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** .......................២៧
៣.២.១.ការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន ............................................................ ២៧
៣.២.២.ការជំនុំជម្រះបណ្តឹងឧទ្ធរណ៍.................................................................................. ២៧
**សេចក្តីសន្និដ្ឋាន** ....................................................................................................២៨
**អនុសាសន៍**...............................................................................................................២៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ក្រមនីតិវិធីរដ្ឋប្បវេណី គឺជាបទដ្ឋានគតិយុត្តដែលបានកំណត់អំពីបែបបទរបស់តុលាការ និងភាគីនៃរឿងក្តីត្រូវប្រតិបត្តិតាមនៅក្នុងដំណើរការនៃការដោះស្រាយវិវាទក្នុងរឿងក្តីរដ្ឋប្បវេណី ដើម្បីធ្វើឱ្យការដោះស្រាយវិវាទមានភាពឆាប់រហ័ស និងទទួលបានយុត្តិធម៌ដល់គូភាគី។ ក្នុងនោះផងដែរ ដោយគោរពគោលការស្វ័យភាពបុគ្គលឯកជន ភាគីអាចធ្វើការសះជាគ្នា នៅក្នុងគ្រប់ដំណាក់កាលក្នុងនីតិវិធីបណ្តឹង ឬ ក៏តុលាការព្យាយាមផ្សះផ្សារផងដែរ ។ ដូចនេះហើយតួអង្គដែលសំខាន់នៅក្នុងការដឹកនាំនីតិវិធីក្នុងការដោះស្រាយវិវាទជូនភាគីនោះគឺតុលាការ ដែលតំណាងដោយរដ្ឋក្នុងការដោះស្រាយវិវាទជូនភាគីតាមរយៈការទាមទារតាមផ្លូវបណ្តឹងដែលត្រូវដាក់មកតុលាការ ។ ទន្ទឹមនឹងនោះ ដើម្បីកុំឲ្យបាត់បង់នូវផលប្រយោជន៍របស់គូភាគី នាពេលដែលមានពាក្យបណ្តឹងមកដល់នោះ តុលាការគួរយកចិត្តទុកដាក់ក្នុងការសម្រេចសេចក្តីឲ្យបានសមស្រប និងគោរពតាមនីតិវិធីច្បាប់។ ក្រោយពីមានការដាក់ពាក្យបណ្តឹងមកកាន់តុលាការរួចហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលយ៉ាងរហ័ស និងកោះហៅគូភាគី ។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជានីតិវិធីដំបូងដែលមានសារៈសំខាន់ មុនឈានដល់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ព្រោះជាដំណាក់កាលបើកសិទ្ធិឲ្យគូភាគីអះអាងអំពីអត្ថិភាព ឬ នត្ថិភាព នៃសិទ្ធិទាមទារ ចំពោះអង្គហេតុណាខ្លះ ជាអង្គហេតុដែលមាន ឬ គ្មានវិវាទ នៃរឿងក្តីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់ ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីដែលធ្វើឡើងដើម្បីរៀបចំការអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីយល់មិនស្របគ្នា និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនោះ មុនឈានដល់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ហេតុដូចនេះទើបបានជា យើងខ្ញុំបានធ្វើការស្រាវជ្រាវលើប្រធានបទនេះឡើងក្រោម បញ្ហាដែលចោទសួរថា តើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលធ្វើឡើងយ៉ាងដូចម្តេច ? និងមានសកម្មភាពអ្វីខ្លះដែលត្រូវធ្វើឡើងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

មូលហេតុដែលជ្រើសរើសប្រធានបទ "នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល" មកធ្វើការស្រាវជ្រាវ និងចងក្រងប្រធានបទសារណានេះឡើង គឺធ្វើមានគោលបំណងដូចខាងក្រោម៖

- ដើម្បីយល់ដឹងនិងប្រមូលធាតុចូល នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។
- យល់ច្បាស់អំពីលំហូរនីតិវិធី និងសកម្មភាពនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

- ដើម្បីទុកជាឯកសារសម្រាប់ការសិក្សាស្រាវជ្រាវបន្ថែម ទាក់ទងនិងទ្រឹស្តីគតិយុត្ត រួមទាំងការអនុវត្តនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

## ៤.សារៈសំខាន់នៃការជ្រើសរើសប្រធានបទ

ចង់បង្ហាញឲ្យអ្នកសិក្សាគ្រប់មជ្ឈដ្ឋាន ស្វែងយល់ឲ្យបានស៊ីជម្រៅទៅលើ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទុកជាឯកសារសម្រាប់អ្នកស្រាវជ្រាវ ពោលគឺ នីតិវិធីដំបូងដែលមានសារៈសំខាន់ដែលក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ ដែលតុលាការត្រូវរៀបចំការអះអាង ដើម្បីដឹងអង្គហេតុណាខ្លះ នាំឱ្យមានមូលហេតុគតិយុត្ត នៃការទាមទារ ឬ ការច្រានចោលចំពោះការទាមទាររបស់ភាគី ដែលធ្វើឱ្យតុលាការ អាចកំណត់ចំណុចវិវាទនៃរឿងក្តី រួមទាំងរៀបចំភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទនៃរឿងក្តីនោះ មួយវិញទៀតនីតិវិធីនេះគឺជាការរៀបចំជាមុននូវឯកសារត្រៀម នូវមធ្យោបាយតទល់ ឬ ការពារខ្លួន និងភស្តុតាងទាក់ទងអង្គហេតុដែលភាគីត្រូវអះអាង និងដាក់មកតុលាការ មុនឈានដល់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីធានាឱ្យបាននូវការជម្រះក្តីដោយការទាញហេតុផលដោយផ្ទាល់មាត់មួយ ដែលជាទីពេញចិត្ត និងដើម្បីទទួលបាននូវសាលក្រមមួយដែលឆ្លើយតបទៅនឹងការពិត ។

## ៥.វិសាលភាពនៃការស្រាវជ្រាវ

ដើម្បីសម្រេចបាននូវការស្រាវជ្រាវលើប្រធានបទខាងលើនេះ យើងខ្ញុំបានធ្វើការសិក្សានូវឯកសារដែលមានលក្ខណៈ ផ្តោតទៅលើទ្រឹស្តីច្បាប់ ដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៦ ព្រមទាំងសៀវភៅសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ នីតិវិធីបណ្តឹង និងមានការណែនាំពីលោកគ្រូ អ្នកគ្រូ រួមទាំងឯកសារពាក់ព័ន្ធផ្សេងៗទៀត ដែលរួមបញ្ចូលគំនិតបន្ថែម ។

## ៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

តាមរយៈលទ្ធផលនៃការស្រាវជ្រាវសារណានេះ យើងខ្ញុំបានបែងចែកប្រធានបទ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះជា៣(បី) ជំពូកដូចខាងក្រោម៖

**ជំពូកទី១៖ សញ្ញាណនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**ជំពូកទី២៖ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**ជំពូកទី៣៖ ការបញ្ចប់ និង អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

ខ្លឹមសារនៃជំពូកនីមួយៗខាងលើនេះ នឹងបង្ហាញជូនលម្អិតនូវខ្លឹមសារទាំងស្រុងក្នុងសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំដូចខាងក្រោម។

# ជំពូកទី១
# សញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីមួយដែលយកមកអនុវត្តនៅក្នុងរឿងក្តីរដ្ឋប្បវេណី ដែលនីតិវិធីនេះផងដែរធ្វើឡើងក្នុងគោលបំណងដើម្បីរៀបចំនូវសេចក្តីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលភាគីយល់មិនស្របគ្នា និងរៀបចំនូវភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់ [1]។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺវាបានផ្តល់ឱកាសដល់ភាគីក្នុងការគោរពគោលការណ៍ចំពោះមុខ[2] និងការដាក់នូវមធ្យោបាយការពារ និងមធ្យោយបានតទល់តាមផ្លូវច្បាប់[3] ដែលនេះជាមូលដ្ឋានគ្រឹះដើម្បីឈានទៅដល់ការសម្រេចសេចក្តីប្រកបភាពយុត្តិធម៌ និងឆាប់រហ័ស[4] ។

## ១.១.គោលការណ៍នានានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### ១.១.១ គោលការណ៍ចំពោះមុខ

ដើម្បីធានាបាននូវសិទ្ធិទាមទារឱ្យសាកសួរដោយមានប្រសិទ្ធិភាព ការជម្រះក្តីត្រូវតែធ្វើឡើងដោយការកោះហៅភាគីទាំងសងខាងឱ្យមកបង្ហាញខ្លួនក្នុងកាលបរិច្ឆេទតែមួយ ដើម្បីឱ្យភាគីធ្វើការតទល់ចំពោះមុខដាក់គ្នាដោយផ្ទាល់។ ប្រសិនបើអនុញ្ញាតឱ្យតុលាការអាចកោះហៅភាគីតែម្ខាង ហើយស្តាប់ការអះអាងរបស់ភាគីនោះដោយពុំមានវត្តមានរបស់ភាគីម្ខាងទៀតនោះអាចនឹងប៉ះពាល់ទៅដល់ទំនុកចិត្តរបស់ភាគី ទៅលើភាពយុត្តិធម៌នៃការវិនិច្ឆ័យ។ ហេតុដូចនេះហើយ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ថា ក្នុងករណីណា ក៏ភាគីមិនអាចត្រូវបានជំនុំជម្រះក្តីដោយមិនបានសាកសួរ ឬ កោះហៅ ហើយក្នុងករណីណាក៏ដោយ តុលាការត្រូវគោរពគោលការណ៍ចំពោះមុខ[5]។ ម្យ៉ាងវិញទៀត នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចជានីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវធ្វើឡើងក្នុងកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន[6]។ ដូចនេះ នៅពេលដែលតុលាការធ្វើការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូងតុលាការត្រូវគិតពិចារណាអំពីលទ្ធភាពរបស់គូភាគីថា តើភាគីទាំងសងខាងអាចចូលរួមបានដែរ ឬទេ ដោយតុលាការត្រូវធ្វើការថ្លឹងថ្លែងអំពីចម្ងាយផ្លូវ និងមធ្យោបាយក្នុងការធ្វើដំណើរដើម្បីចូលរួមរបស់គូភាគីជាដើម ។

[1] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ១០៣

[2] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ កថាខណ្ឌទី២ នៃមាត្រា ៣

[3] សូមមើល នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ៩៣

[4] សូមមើល ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ៤

[5] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា៣

[6] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា១០៥ និងមាត្រា១១៥

### ១.១.២ គោលការណ៍ជាអសាធារណៈ

ក្រៅពីគោលការណ៍ចំពោះមុខ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតុលាការត្រូវគោរពនូវ គោលការណ៍អសាធារណៈ។ គោលការណ៍អសាធារណៈ គឺជាគោលការណ៍មួយដែលអនុញ្ញាតឱ្យតុលាការ អាចធ្វើនីតិវិធីសម្រាប់ការទាញហេតុផល ដោយពុំចាំបាច់មានការចូលរួមពីសាធារណៈជននោះទេ ។ ដែលគោលការណ៍នេះនៅពេលដែលតុលាការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលអាចធ្វើទៅបាននៅចំពោះ មុខគូភាគីនៃរឿងក្តីតែប៉ុណ្ណោះ ប៉ុន្តែតុលាការក៏អាចអនុញ្ញាតឱ្យជនដែលយល់ឃើញថាសមរម្យ ដូចជា សមាជិកគ្រួសាររបស់ភាគី ឬ ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធដទៃទៀតចូលស្តាប់ជាអ្នកអង្កេតការណ៍បាន[7]។ ការកំណត់ដោយពុំចាំបាច់ធ្វើជាសាធារណៈបែបនេះ គឺដោយសារតែនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការគ្រាន់តែធ្វើការកំណត់នូវចំណុចវិវាទ តាមរយៈការអះអាងរបស់ភាគី និងគ្រាន់ តែរៀបចំនូវភស្តុតាងដែលត្រូវពិនិត្យប៉ុណ្ណោះ[8]។ ម្យ៉ាងវិញទៀត ចំពោះទីកន្លែងដែលត្រូវធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការអាចធ្វើនៅទីកន្លែងណាក៏បានដែរឱ្យតែតុលាការយល់ឃើញថា សមរម្យ ដោយមិនចាំបាច់ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះនៅសាលសវនាការនោះទេ ដែលខុសពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដែលចាំបាច់ត្រូវធ្វើការទាញហេតុផលផ្ទាល់មាត់នៅក្នុងសាលសវនាការ ជាសាធារណៈ លើកលែងតែភាពជាសាធារណៈនេះបណ្តាលឱ្យខូចសណ្តាប់ធ្នាប់សាធារណៈ ឬ ករណីដែល មានបញ្ញត្តិពិសេសនៅក្នុងច្បាប់តែប៉ុណ្ណោះ[9]។

### ១.១.៣ គោលការណ៍តុលាការអកម្ម

នៅក្នុងដំណើរការដោះស្រាយវិវាទនៃរឿងក្តីរដ្ឋប្បវេណី ក្រៅពីគោលការណ៍ដែលបានលើកឡើងខាងលើនោះ តុលាការត្រូវគោរពនូវគោលការណ៍ជាតុលាការអកម្មផងដែរ ។ ព្រោះតុលាការមិនអាចយកអង្គហេតុណា ដែលភាគីណាមួយមិនបានអះអាង មកធ្វើជាមូលហដ្ឋាននៃសាលក្រមបានឡើយ[10]។ ដូចនេះនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការមានតួនាទីដឹកនាំសម្របសម្រួលនីតិវិធី ដើម្បីធ្វើយ៉ាងណាកំណត់នូវចំណុចវិវាទនៃរឿងក្តីក្នុងការយកទៅជំនុំជម្រះនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ។ ហើយភាគីត្រូវធ្វើការស្រាវជ្រាវឱ្យបានលម្អិតជាមុននូវទំនាក់ទំនងនៃអង្គហេតុចំពោះសាក្សី ភស្តុតាងផ្សេងៗ ដើម្បីធ្វើការអះអាង និងបញ្ជាក់ឱ្យបានគ្រប់គ្រាន់ច្បាស់លាស់ក្នុងបណ្តឹង[11]។

---

[7] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា១០៥ កថាខណ្ឌទី២

[8] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីបណ្តឹង ទំព័រ៧៥

[9] ក្រមនីវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា១១៥ កថាខណ្ឌទី២

[10] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ៩៥

[11] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា៩២

## ១.២.ភាពចាំបាច់នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅពេលដាក់ពាក្យបណ្ដឹង គឺដើម្បីចេញសាលក្រមទៅលើបណ្ដឹង តុលាការចាំបាច់ត្រូវតែឆ្លងកាត់នូវការទាញហេតុផលដោយផ្ទាល់មាត់[12]។ ដើម្បីធានាឱ្យបាននូវការជម្រះក្ដីដោយការទាញហេតុផលដោយផ្ទាល់មាត់មួយដែលជាទីពេញចិត្ត និងដើម្បីទទួលបាននូវសាលក្រមមួយដែលឆ្លើយតបទៅនឹងការពិត ចាំបាច់ត្រូវមាននីតិវិធីត្រៀមរៀបចំការទាញហេតុផល[13]។ ជាងនេះទៅទៀត តុលាការត្រូវកោះហៅភាគីទាំងសងខាង ដោយកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងដាក់ឯកសារត្រៀម ដើម្បីរៀបចំសេចក្ដីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទ និងពិនិត្យភស្តុតាងទាក់ទងនិងចំណុចវិវាទ ដើម្បីឱ្យចំណុចនៃអង្គហេតុ និង អង្គច្បាប់ដែលទាក់ទងនឹងបណ្ដឹង មានភាពច្បាស់លាស់ តុលាការអាចសាកសួរភាគី ឬ ឱ្យភាគីអះអាង ឬ បញ្ជាក់ភស្តុតាង ចំពោះចំណុចនោះ[14]។

### ១.២.១ គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរៀបចំនូវសេចក្ដីអះអាងរបស់ ភាគីបំភ្លឺនូវចំណុចវិវាទនៃរឿងក្ដីដែលគូភាគីយល់មិនស្របគ្នា និង រៀបចំភស្តុតាងដែលទាក់ទងនឹងចំណុច វិវាទនៃរឿងក្ដីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្ដីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឲ្យបានល្អិតល្អន់[15]។ ហើយក៏ជាឱកាសដើម្បីឱ្យភាគីបានជួបជុំគ្នានិយាយគ្នា និងធ្វើការ ផ្សះផ្សាចំពោះមុខច្បាប់ បន្ថែមទៀតនោះចំណុចនៃអង្គហេតុ និងអង្គច្បាប់ ដែលទាក់ទងនឹងបណ្ដឹងមាន ភាពមិនច្បាស់លាស់តុលាការអាចសាកសួរភាគី ឬ ឱ្យភាគីអះអាង ឬ បញ្ជាក់ភស្តុតាងចំពោះចំណុចនោះ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល[16]។ នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ភាគីនីមួយៗតែងលើកឡើងនូវអង្គហេតុផ្សេងៗដែលខ្លួនយល់ថាមានប្រយោជន៍សម្រាប់ខ្លួនឯង ដោយពុំគិតថាអង្គហេតុទាំងនោះ មាន ឬ គ្មានសារៈសំខាន់ចំពោះរឿងក្ដីនោះទេ ។ នៅក្នុងពេលជាមួយគ្នា ភាគីនីមួយៗ តែងតែតវ៉ាចំពោះការលើកឡើងនូវអង្គហេតុទាំងអស់របស់ភាគីម្ខាងទៀត ហើយតែងតែព្យាយាមដាក់ភស្តុតាងទាំងឡាយណាដែលខ្លួនគិតថាមានប្រយោជន៍សម្រាប់ខ្លួន ។ ក៏ប៉ុន្តែ ការធ្វើបែបនេះ នឹងនាំឱ្យការជម្រះក្ដីមានភាពស្មុគស្មាញ និងអូសបន្លាយដោយឥតប្រយោជន៍ និងធ្វើឱ្យមានការលំបាកក្នុងការស្វែងរកការពិត ។ ហេតុដូច្នេះមុននឹងការចាប់ផ្ដើមធ្វើការទាញហេតុផលផ្ទាល់មាត់ ក្រមនីតិវិធីរដ្ឋប្បវេណីតម្រូវឱ្យមាននីតិវិធិត្រៀមសម្រាប់ការទាញហេតុផល ដើម្បីឱ្យតុលាការ ពិគ្រោះជាមួយភាគីទាំងសងខាង ត្រូវរៀបចំសេចក្ដីអះអាងរបស់ភាគី និងត្រូវបំភ្លឺនូវចំណុចវិវាទ តាមវិធីសាស្ត្រ ៖

ស្នើឱ្យភាគីធ្វើការដកសេចក្ដីអះអាងអំពីអង្គហេតុដែលមិនមានប្រយោជន៍ ចំពោះការសម្រេចអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលកម្មវត្ថុបណ្ដឹង និង ផាត់ចោលនូវអង្គហេតុដែលពុំមានវិវាទ ។

---

[12] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ កថាខណ្ឌទី១ នៃមាត្រា ១១៤

[13] សេចក្ដីពន្យល់អំពីនីតិវិធីរដ្ឋប្បវេណីភាគ១ ស្ដីពី នីតិវិធីបណ្ដឹង ទំព័រ ៧២

[14] សូមមើល ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ៨០ ,មាត្រា ៩០ ,មាត្រា ១០១ និងមាត្រា ១០៣

[15] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ១០៣

[16] សូមមើល ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ៩០

ជាងនេះទៅទៀត ចំពោះភស្តុតាង ដែលត្រូវពិនិត្យទាក់ទងនឹងចំណុចវិវាទ តុលាការត្រូវធានាឱ្យបាននូវការពិនិត្យដោយសមូហវិធី ដោយត្រូវយកចិត្តទុកដាក់តែទៅលើភស្តុតាងដែលសំខាន់ និង មានតម្លៃប៉ុណ្ណោះ ។ ដោយសារហេតុផលនេះហើយបាននៅមុនជម្រះក្តីដោយការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវរៀបចំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល[17]។

**១.២.២ ការដាក់ឯកសារត្រៀម**

ក្រមនីតិវិធីរដ្ឋប្បវេណី បានបង្កើតនូវប្រព័ន្ធនៃឯកសារត្រៀម ដើម្បីប្រើប្រាស់ឱ្យមានប្រសិទ្ធភាពនូវកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ។ បានន័យថាតុលាការអាចបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀម នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាល់មាត់បាន[18]។ ឯកសារត្រៀម គឺជាឯកសារដែលភាគីនីមួយៗ ជូនដំណឹងជាមុនទៅតុលាការ និងភាគីម្ខាងទៀត អំពីចំណុចដែលខ្លួននឹងធ្វើសេចក្តីថ្លែងការណ៍នៅកាលបរិច្ឆេទបន្តបន្ទាប់ ។ នៅក្នុងឯកសារត្រៀមត្រូវសរសេរអំពីមធ្យោបាយតទល់ ឬ ការពារខ្លួន និងសេចក្តីថ្លែងការណ៍ ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនពីភាគីម្ខាងទៀត[19]។ ម្យ៉ាងទៀត នៅក្នុងឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូង ត្រូវសរសេរអំពីការឆ្លើយតប ចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរទាមទារនៅក្នុងពាក្យបណ្តឹង និងការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង និងអង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹងជាអាទិ៍[20]។ ហេតុនេះហើយ ឯកសារត្រៀមបែបនេះ គេហៅថា "ឯកសារចម្លើយ "។ ក្នុងករណីដែលដើមចោទ បានសរសេរនៅក្នុងពាក្យបណ្តឹង និងអង្គហេតុនៃការទាមទារ ព្រមទាំងអង្គហេតុសំខាន់ៗដែលទាក់ទងនឹងអង្គហេតុដែលទាមទារឱ្យមានបញ្ជាក់ ការសរសេរនោះ មានអត្ថន័យជាការដាក់មធ្យោបាយតទល់ ។ ដូច្នេះ ពាក្យបណ្តឹងដែលមានសរសេរនូវចំណុច និងអង្គហេតុទាំងនេះត្រូវចាត់ទុកជាឯកសារត្រៀមផងដែរ[21]។ ដោយសារក្រមនីតិវិធីរដ្ឋប្បវេណី បានជ្រើសរើសយកគោលការណ៍នៃការជម្រះក្តីដោយផ្ទាល់មាត់ហេតុនេះហើយ ចំណុចទាំងឡាយដែលមានសរសេរនៅក្នុងឯកសារត្រៀម មិនអាចចាត់ទុកថាជាខ្លឹមសារនៃការទាញហេតុផលតែម្តងបានទេ ។ ចំណុចនានាដែលមានសរសេរនៅក្នុងឯកសារត្រៀម ដែលត្រូវបានដាក់សម្រាប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវយកមកពិចារណានៅពេលធ្វើការចាត់ចែង ឬ រៀបចំការអះអាង និងភស្តុតាង នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប្រសិនបើចំណុចទាំងនោះ ត្រូវបានភាគីថ្លែងដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទនោះ ។ ប៉ុន្តែ ប្រសិនបើចំណុចទាំងនោះ មិនត្រូវបានភាគីថ្លែងឡើងនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ដោយចាត់ជាផ្នែកមួយនៃលទ្ធ

[17] សូមមើល សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ អំពីនីតិវិធីបណ្តឹង ទំព័រ៧៤

[18] សូមមើល ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ កថាខណ្ឌទី១ នៃមាត្រា ១០១

[19] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ កថាខណ្ឌទី២ នៃមាត្រា ១០១

[20] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ កថាខណ្ឌទី៣ នៃមាត្រា ១០១

[21] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ កថាខណ្ឌទី៤ នៃមាត្រា ៧៥

ផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ ចំណុចទាំងនោះមិនអាចយកទៅធ្វើជាមូលដ្ឋាននៃសាលក្រម បានឡើយ[22]។

### ១.២.៣ ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផលយ៉ាងឆាប់រហ័ស និងសម្រាប់កោះហៅគូភាគី ។ ហើយកាលបរិច្ឆេទដែលត្រូវ កំណត់ក្នុងអំឡុងពេល ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់ លើកលែងតែក្នុងករណីដែលមានមូលហេតុពិសេស[23]។ ការកំណត់បែបនេះ គឺទុកឱកាសសម្រាប់ចុងចម្លើយនឹងមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំការការពារខ្លួន ក្នុងការចាប់ផ្តើមនីតិវិធី នឹងមិនមានការយឺតយ៉ាវ ។

កាលបរិច្ឆេទត្រៀមសម្រាប់ទាញហេតុផល មិនចាំបាច់បើកជាសាធារណៈទេ ។ ប៉ុន្តែ តុលាការអាចឱ្យអ្នកដែលតុលាការយល់ឃើញថាសមរម្យចូលស្តាប់ជាអ្នកសង្កេតការណ៍បាន[24]។ ព្រោះដោយសារតែ នៅកាលបរិច្ឆេទត្រៀមសម្រាប់ទាញហេតុផល តុលាការគ្រាន់តែធ្វើការកំណត់នូវចំណុចវិវាទតាមរយៈការរៀបចំការអះអាងរបស់ភាគី និងគ្រាន់តែរៀបចំនូវភស្តុតាងដែលត្រូវពិនិត្យតែប៉ុណ្ណោះ[25]។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ តុលាការអាចអនុញ្ញាតឱ្យជនដែលខ្លួនយល់ឃើញថាសមរម្យ ដូចជាសមាជិកគ្រួសាររបស់ភាគី ឬ ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធដទៃទៀត ចូលស្តាប់ជាអង្កេតការណ៍បាន ។ ចំពោះការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យអ្នកសង្កេតការណ៍ចូលស្តាប់ គឺជាឆន្ទានុសិទ្ធិរបស់តុលាការ ។ នៅពេលធ្វើការសម្រេចអំពីការការអនុញ្ញាត ឬ មិនអនុញ្ញាត តុលាការពិចារណាអំពីមូលហេតុនៃការស្នើសុំចូលស្តាប់ ព្រមទាំងមតិភាគីផងដែរ ។ ក្នុងករណីដែលការស្នើសុំ ត្រូវធ្វើឡើងដោយបុគ្គលដែលមានការពាក់ព័ន្ធនឹងរឿងក្តី ជាគោលការណ៍តុលាការអាចផ្តល់ការអនុញ្ញាតចំពោះការស្នើនោះបាន ប្រសិនបើការចូលស្តាប់នោះ មិនទំនងជានឹងបង្កបញ្ហាដល់ការជម្រះសេចក្តីទេ ។ ប៉ុន្តែ ក្នុងករណីដែលយល់ឃើញថា ភាគីណាអាចរងការបះពាល់ផ្លូវចិត្តដោយសារតែវត្តមានរបស់បុគ្គលដែលពាក់ព័ន្ធនោះ តុលាការមិនត្រូវអនុញ្ញាតឱ្យបុគ្គលនោះចូលស្តាប់ទេ[26]។

### ១.២.៤ កោះហៅគូភាគី ដើម្បីចូលរួមក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចចូលរួមបាន[27]។ ដោយយោងទៅតាមគោលការណ៍ចំពោះមុខ តុលាការត្រូវធានាបើកឱកាសអោយភាគីសងខាងចូលរួម ក្នុងការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហេតុដូច្នេះតុលាការត្រូវកំណត់កាលបរិច្ឆេទដើម្បីធ្វើនីតិវិធីត្រៀម

[22] សៀវភៅសេចក្តីពន្យល់អំពី ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ នីតិវិធីបណ្តឹង ទំព័រ៧៣

[23] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ៨០

[24] សូមមើល ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ កថាខណ្ឌទី២ នៃមាត្រា ១០៥

[25] សូមមើល ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០៣

[26] សៀវភៅសេចក្តីពន្យល់អំពី ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ នីតិវិធីបណ្តឹង ទំព័រ៧៦

[27] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ កថាខណ្ឌទី១ នៃមាត្រា ១០៥

សម្រាប់ទាញហេតុផល ដោយកោះហៅភាគីទាំងសងខាង[28]។ បន្ទាប់ពីបានកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយ តុលាការត្រូវកោះហៅភាគីទាំងសងខាងឱ្យចូលរួមក្នុងនីតិវិធី ដែលត្រូវធ្វើការបញ្ជូនដីកាកោះតាមកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទៅភាគី ដែលធ្វើឡើងដោយប្រតិបត្តិការបញ្ជូនដែលកំណត់ដោយច្បាប់ ប៉ុន្តែ ទោះជាយ៉ាងណាងក៏ដោយ តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ទោះបីជាភាគីម្ខាងមិនមានវត្តមានក៏ដោយ ក្នុងករណីដែលតុលការបានបញ្ជូនដីកាកោះ និង បានផ្តល់ឱកាសឱ្យភាគីនោះបង្ហាញខ្លួនហើយ [29]។

[28] សូមមើល ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ កថាខណ្ឌទី១ នៃមាត្រា ៨០

[29] សៀវភៅសេចក្តីពន្យល់អំពី ក្រមនីតិវិធីរដ្ឋប្បវេណី ភាគី១៖ នីតិវិធីបណ្តឹង ទំព័រ៧៥

# ជំពូកទី២
# នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ការជំនុំជម្រះលើបណ្តឹង ត្រូវប្រព្រឹត្តទៀងដោយការងារសហការគ្នា រវាងតុលាការ និងភាគីទាំងសងខាងដែលជាប្រធាននៃបណ្តឹង ដោយផ្អែកវិធាន និងការបែងចែងតួនាទីរៀងៗខ្លួន ។ ក្រមនីតិវិធីរដ្ឋប្បវេណី ចែងអំពីការបែងចែងតួនាទី ឬ ម្យ៉ាងទៀតថាសិទ្ធិអំណាចនិងការទទួលខុសត្រូវ ។ ការគ្រប់គ្រងលើនីតិវិធី ការដឹកនាំនីតិវិធីឱ្យដើរទៅមុខ ព្រមទាំងការចាត់ចែងនិងរៀបចំការជំនុំជម្រះ គឺជាសិទ្ធិអំណាចនិងការទទួលខុសត្រូវចម្បង របស់តុលាការ ។ ដោយឡែក ការកំណត់នូវចំណុចវិវាទដែលជាកម្មវត្ថុនៃការជំនុំជម្រះ និងការសម្រេចសេចក្តី ការបំភ្លឺអំពីអង្គហេតុនៃរឿងក្តី និងការផ្តល់ឯកសារជាមូលដ្ឋានសម្រាប់ការសម្រេចសេចក្តី គឺជាសិទ្ធិអំណាចនិងការទទួលខុសត្រូវ របស់ភាគី [30]។ ដោយឡែកនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឃើញថាមានសកម្មភាពរបស់ភាគី និងតុលាការ ដែលមានបែងចែងដូចខាងក្រោមដោយផ្អែកលើបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ២.១.សកម្មភាព តុលាការ និង ភាគី នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### ២.១.១.សកម្មភាពរបស់តុលាការ

ក្នុងគោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរកឱ្យឃើញនៅចំណុចវិវាទនៃរឿងក្តីរបស់គូភាគីដែលមិនយល់ស្របគ្នា និង រៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់ ។ ហេតុដូច្នេះកិច្ចនៃសកម្មភាពរបស់តុលាការមានតួនាទីយ៉ាងសកម្ម ដែលក្រមនីតិវិធីរដ្ឋប្បវេណីបានចែងដូចជាការគ្រប់គ្រងនីតិវិធី និងការដឹកនាំនីតិវិធីទៅមុខដើម្បីឱ្យចំណុចនៃអង្គហេតុ និង អង្គច្បាប់ដែលទាក់ទងនឹងបណ្តឹងមានភាពច្បាស់លាស់ ប៉ុន្តែទោះបីជាកំណត់ចំណុចវិវាទនៃរឿងក្តីនោះហើយ តុលាការក៏ត្រូវធ្វើការសម្របសម្រួលជាមួយភាគីទាំងសងខាង ដើម្បីបញ្ចប់វិវាទផងដែរ ដូចជាការធ្វើការផ្សះផ្សាជាដើម ។

#### ២.១.១.១ ការផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបានទោះបីជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ[31]។ ដោយនីតិវិធីរដ្ឋប្បវេណី មានគោលបំណងធ្វើការកំណត់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ និងកាតព្វកិច្ចតាមច្បាប់សារធាតុ ដែលអាចចាត់ចែងបាន ដោយផ្អែកលើការព្រមព្រៀងរវាងភាគី ដូច្នេះ ទោះបីជាពេលដែលនីតិវិធីបណ្តឹងត្រូវបានចាប់ផ្តើមហើយក៏ដោយ ប្រសិនបើភាគីបានកំណត់សិទ្ធិ ឬ កាតព្វកិច្ច មានអត្ថិភាព ឬ នត្ថិភាព តាមរយៈ

[30] សូមមើល សៀវភៅសេចក្តីពន្យល់អំពី ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ នីតិវិធីបណ្តឹង ជំពូកទី២ ទំព័រ៧៦

[31] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ៩៧

ការសះជាហើយភាគីសម្រេចចិត្តបញ្ចប់វិវាទនោះ គឺជាលទ្ធផលដែលចង់បាន[32]។ ហេតុនេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណី នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលជាសកម្មភាពដំបូងនៃការជម្រះក្តី តុលាការត្រូវណែនាំឱ្យភាគីទាំងសងខាង សះជានឹងគ្នា។

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវសាកល្បងផ្សះផ្សាជាដំបូងសិនលើក លែងតែយល់ឃើញថាមិនសមរម្យ[33]។ ក្នុងករណីតុលាការយល់ឃើញថា ការព្យាយាមសាកល្បងផ្សះផ្សាគ្នា មិនសមរម្យទេ ដូចជាក្នុងករណីដែលសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹង គឺជាប្រភេទនៃសិទ្ធិ ឬ កាតព្វកិច្ចដែលមិនអាចចាត់ចែងបានដោយគ្រាន់តែផ្អែកលើការព្រមព្រៀងរបស់ភាគី ឬ ក្នុងករណីដែលអាកប្បកិរិយារបស់ភាគីបង្ហាញយ៉ាងច្បាស់ថា ពួកគេគ្មានឆន្ទៈធ្វើការផ្សះផ្សាទេនោះ តុលាការមិនចាំបាច់ណែនាំឱ្យភាគីសះជានឹងគ្នាឡើយ[34]។

នៅពេលកំពុងធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប្រសិនបើចៅក្រមយល់ឃើញថាមាន លទ្ធភាពច្រើនក្នុងការផ្សះផ្សា ចៅក្រមគួរគិតពិចារណាប្តូរគោលបំណងនៃកាលបរិច្ឆេទនោះ ពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ទៅជាកាលបរិច្ឆេទនៃការផ្សះផ្សាវិញ ឬ ក៏ភាគីអាចធ្វើការផ្សះផ្សានៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ ប៉ុន្តែការផ្សះផ្សានេះអាចធ្វើនៅក្រៅទីតាំងតុលាការក៏បានដែរ ប្រសិនបើតុលាការយល់ថាសមរម្យ [35]។

### ២.១.១.២.ការដឹកនាំ និងការរៀបចំការអះអាងរបស់ភាគី

ការរៀបចំការអះអាងរបស់ភាគី គឺជាតួនាទីរបស់តុលាការដែលជាអ្នកដឹកនាំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយឱ្យភាគីខាងដើមចោទ និងចុងចម្លើយធ្វើការថ្លែងការណ៍ទៅតាមលំដាប់លំដោយអំពីអង្គហេតុអត្ថិភាព ឬ នត្ថិភាព និងទំនាក់ទំនងគតិយុត្តិ នៃសិទ្ធិរបស់ភាគីដែលត្រូវអះអាង ដើម្បីឱ្យតុលាការដឹងអំពីអង្គហេតុនៃការទាមទារ និងអង្គហេតុនៃការច្រានចោលរបស់ភាគី ហេតុនេះហើយតុលាការចាំបាច់រៀបចំការអះអាងរបស់ភាគីដើម្បីឱ្យដឹងថាអង្គហេតុណាខ្លះជាអង្គហេតុដែលមានចំណុចវិវាទ និងអង្គហេតុណាខ្លះជាអង្គហេតុមិនមានចំណុចវិវាទ។ ម្យ៉ាងទៀតការរៀបចំអះអាងពោល តុលាការគោរពការជម្រះក្តីដោយផ្ទាល់មាត់ ដូច្នេះភាគីត្រូវចាំបាច់ត្រូវធ្វើការអះអាងអំពីអត្ថិភាពនៃសិទ្ធិ ឬ នត្ថិភាពនៃសិទ្ធិ និងទំនាក់ទំនងគតិយុត្តរបស់ខ្លួនតាមរយៈការថ្លែងការណ៍ ឬ មធ្យោបាយរបស់ខ្លួន ភស្តុតាងនៃអង្គហេតុដើម្បីឱ្យតុលាការបានដឹងអំពីអង្គហេតុនោះ ។ ការថ្លែងការណ៍របស់ភាគី អាចធ្វើឡើងដោយផ្ទាល់មាត់ ឬ អាចធ្វើឡើងជាលាយលក្ខណ៍អក្សរក៏បាន។ ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវដឹកនាំចាត់ចែងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងត្រូវ

[32] សេចក្តីពន្យល់អំពីនីតិវិធីរដ្ឋប្បវេណី ទំព័រ ៧៦, ៧៧
[33] មាត្រា ១០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី
[34] សេចក្តីពន្យល់អំពីនីតិវិធីរដ្ឋប្បវេណី ភាគ១៖ នីតិវិធីបណ្តឹង ទំព័រ៧៧
[35] សូមមើល ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ មាត្រា ២២០

ដឹកនាំចាត់ចែងការទាញហេតុផលផ្ទាល់មាត់ ។ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់និយាយ និងអាចហាមឃាត់ជនដែលមិនស្ដាប់បញ្ជារបស់ខ្លួនមិនឱ្យនិយាយបាន[36]។

**ក.ការថ្លែងការណ៍របស់ដើមចោទ**

ទោះបីជាមានពាក្យបណ្ដឹងដែលធ្វើឡើងជាលាយលក្ខណ៍អក្សរ បានដាក់ចូលមកតុលាការក៏ពិតមែនដោយផ្អែកលើគោលការណ៍នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលបានកំណត់ឱ្យមានការជម្រះក្ដីដោយផ្ទាល់មាត់ និងគោលការណ៍ចំពោះមុខ ដែលទាមទារឱ្យមានការសាកសួរតទល់គ្នានោះ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាដំបូងចៅក្រមត្រូវឱ្យភាគីខាងដើមចោទធ្វើសេចក្ដីថ្លែងការណ៍អះអាង អំពីពាក្យបណ្ដឹងរបស់ខ្លួន។ ការថ្លែងការណ៍នេះដើមចោទត្រូវបញ្ជាក់អំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលជាការទាមទារតាមផ្លូវបណ្ដឹង។ បន្ថែមពីនេះ ដើមចោទត្រូវធ្វើការអះអាងបញ្ជាក់ឱ្យច្បាស់លាស់អំពីការបង្កើតសិទ្ធិ ឬ ទំនាក់ទនងគតិយុត្ត និងបញ្ជាក់ឱ្យច្បាស់អំពីអត្ថិភាព ឬ នត្ថិភាព នៃសិទ្ធិក្នុងការទាមទារនោះ។ មានន័យថា ភាគីខាងដើមចោទ ត្រូវធ្វើការអះអាងអំពី មូលហេតុដែលខ្លួនធ្វើបណ្ដឹងទាមទារនេះ ថាតើខ្លួនសំអាងអ្វីបានជាប្ដឹងទាមទារពីចុងចម្លើយ ហើយដល់ពេលដែលត្រូវទាមទារ ឬ មិនទាន់ដល់ពេលដែលត្រូវទាមទារទេ ។ ក្នុងការអះអាងនេះ ភាគីក៏អាចស្នើសុំដាក់ភស្តុតាងដើម្បីបញ្ជាក់អំពីការទាមទាររបស់ខ្លួនដែលបានអះអាងនោះបានផងដែរ។

**ខ.ការថ្លែងការណ៍របស់ចុងចម្លើយ**

បន្ទាប់ពីស្ដាប់ការថ្លែងការណ៍របស់ដើមចោទរួចហើយ ចៅក្រមត្រូវឱ្យភាគីខាងចុងចម្លើយធ្វើសេចក្ដីថ្លែងការណ៍តបទៅនឹងការថ្លែងការរបស់ដើមចោទវិញ ។ ការថ្លែងការណ៍តបរបស់ចុងចម្លើយ អាចជាការទទួលស្គាល់អង្គហេតុ ឬ មិនទទួលស្គាល់នូវអង្គហេតុ ឬ ការទទួលស្គាល់នូវការទាមទារ ឬ ច្រានចោលនូវការទាមទារ របស់ដើមចោទដែលមាននៅក្នុងបណ្ដឹងនៃរឿងក្ដី ។ ការថ្លែងការណ៍របស់ចុងចម្លើយ ក៏ជាមួយជាមធ្យាបាយមួយដើម្បីអះអាងអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដើម្បីការពារខ្លួន ចំពោះអង្គហេតុនៃការទាមទាររបស់ភាគីម្ខាងទៀតផងដែរ ដូច្នេះចុងចម្លើយត្រូវបញ្ជាក់អំពីអង្គហេតុដែលនាំឱ្យច្រានចោលចំពោះការទាមទារតាមកម្មវត្ថុបណ្ដឹង អំពីការបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិ ឬ នត្ថិភាពនៃសិទ្ធិ និងទំនាក់ទំនងគតិយុត្តរបស់ខ្លួនផងដែរ ។

**២.១.១.៣.ការកំណត់ចំណុចវិវាទ**

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ពេលដែលភាគីថ្លែងការណ៍ និងបានអះអាង នូវមធ្យោបាយតទល់ ឬ ការពារខ្លួន ពេលនោះតុលាការត្រូវអនុវត្តសិទ្ធិបំភ្លឺ និងរៀបចំមធ្យោបាយតទល់ ឬ ការពារខ្លួននោះជាពិសេសត្រូវរៀបនិងចំការអះអាងភាគីទាំងសងខាងដើម្បីកំណត់នូវចំណុចវិវាទពិតប្រាកដនៃរឿងក្ដី ហើយតុលាការត្រូវ រៀបចំនូវភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទនោះ ដែលត្រូវធ្វើការពិនិត្យនៅក្នុងការទាញហេតុផល

[36] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ៨៩

ដោយផ្ទាល់មាត់ ប៉ុន្តែចំពោះភស្តុតាងឯកសារតុលាការអាចធ្វើការពិនិត្យត្រឹមកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទតែប៉ុណ្ណោះ ។ នេះជាផ្នែកសំខាន់បំផុតនៃការជម្រះក្ដី នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល[37]។

ចំណុចវិវាទ គឺជាអង្គហេតុចម្បងទាំងឡាយណាដែលគូភាគីយល់មិនស្របគ្នា ។ ដែលអង្គហេតុចម្បង គឺជាអង្គហេតុដែលមានកម្មវត្ថុជាវិវាទតាមផ្លូវច្បាប់ជាក់ស្តែង និងវិវាទនោះអាចដោះស្រាយដោយសាលក្រម[38]។ ការកំណត់ចំណុចវិវាទទៅលើការ**ទទួលស្គាល់** ឬ **មិនទទួលស្គាល់នៃការទាមទារ**នៅក្នុងបណ្ដឹងរបស់ភាគី ។ អង្គហេតុដែលភាគីបាន**សារភាព**នៅចំពោះមុខតុលាការ និង អង្គហេតុដែលតុលាការយល់ឃើញថា មានភាពជាក់ស្តែង តុលាការពុំចាំបាច់ទទួលស្គាល់នោះ ដោយផ្អែកលើភស្តុតាងទេ[39]។ ការ**បដិសេធ** ត្រូវតែមានភស្តុតាងដើម្បីបញ្ជាក់ជាមូលដ្ឋាន ឲ្យតុលាការទទួលស្គាល់[40]។ ចំពោះការបញ្ជាក់មិនដឹង អំពីអង្គហេតុដែលភាគីម្ខាងទៀតបានអះអាង ភាគីនោះ ត្រូវបានសន្មតថា បានតវ៉ាអំពីអង្គហេតុនោះ[41]។ ភាគីនៅ**ស្ងៀម** មិនបានបង្ហាញច្បាស់លាស់ នូវឆន្ទៈតវ៉ា អំពីអង្គហេតុដែលភាគីម្ខាងទៀតបានអះអាង ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ភាគីនោះត្រូវចាត់ទុកថា បានសារភាពអំពីអង្គហេតុនោះ។ ប៉ុន្តែតុលាការគិតពិចារណាអំពីដំណើរការ និងខ្លឹមសារនៃរឿងក្ដី ហើយយល់ឃើញថា ភាគីនោះបានតវ៉ាអំពីអង្គហេតុ[42]។

នៅពេលដែលតុលាការ ត្រូវរៀបចំនូវចំណុចទាំងឡាយណាដែលភាគីចុងចម្លើយទទួលស្គាល់ និង ចំណុចដែលគូភាគីមិនទទួលស្គាល់ដើម្បីកំណត់អំពីចំណុចដែលភាគីមិនយល់ស្របគ្នាដែលជាចំណុចវិវាទនៃរឿងក្ដី ។ បន្ទាប់ពីបានកំណត់នូវចំណុចវិវាទពិតប្រាកដហើយ តុលាការត្រូវរៀបចំនូវភស្តុតាងដែលពាក់ព័ន្ធនឹងចំណុចវិវាទនោះ ដែលត្រូវធ្វើការពិនិត្យ ។

### ២.១.១.៤.ការរៀបចំភស្តុតាងទាក់ទងនិងចំណុចវិវាទ

ជាគោលការណ៍ការពិនិត្យភស្តុតាង ត្រូវធ្វើឡើងតាមការស្នើសុំឱ្យពិនិត្យរបស់ភាគី[43]។ ចំពោះភស្តុតាងដែលអាចទទួលមកពិនិត្យនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន គឺមានតែភស្តុតាងជាឯកសារក្នុងកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទ និងភស្តុតាង[44]។ តុលាការត្រូវចាំបាច់ធ្វើការពិនិត្យលើឯកសារដែលភាគីបានដាក់ ហើយការពិនិត្យភស្តុតាងជាឯកសារនេះ ដែលត្រូវធ្វើឡើងដោយការផ្ដល់នូវឯកសារដែលសាមីភាគីមាន ឬ ដោយដាក់ពាក្យសុំទៅតុលាការឱ្យបង្គាប់ឱ្យម្ចាស់ឯកសារផ្ញើឯកសារនោះមក[45]។ ហេតុនេះហើយបាន

[37] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ នីតិវិធីបណ្ដឹង ទំព័រ៨២

[38] សូមមើល ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ៧៤

[39] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ១២៣ កថាខណ្ឌទី២

[40] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ១២៣ កថាខណ្ឌទី១

[41] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ៩៦ នៃកថាខណ្ឌទី២

[42] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ កថាខណ្ឌទី១ មាត្រា ៩៦

[43] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ មាត្រា ១២៤ កថខណ្ឌទី ១

[44] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ មាត្រា ១០៦

[45] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ មាត្រា ១២៨ កថាខណ្ឌទី១

ជាក្រមនីតិវិធីរដ្ឋប្បវេណី អនុញ្ញាតអាចធ្វើការពិនិត្យភស្តុតាងជាឯកសារ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានត្រឹមកម្រិតដែលចាំបាច់ដើម្បីរៀបចំ ចំណុចវិវាទ[46]។ ការស្នើសុំឱ្យពិនិត្យភស្តុតាង ក៏អាចធ្វើមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ មុនកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់បានដែរ [47] ។ ចំពោះភស្តុតាងដែលតុលាការ យកមកពិនិត្យគឺត្រូវតែជាភស្តុតាង ដែលជាឯកសារដែលចាំបាច់ ហើយមានទំនាក់ទំនងជាមួយអង្គហេតុ ប៉ុន្តែសម្រាប់ភស្តុតាងដែលជាសាក្សី គឺត្រូវដាក់ស្នើសុំទៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់វិញ ។ ផ្ទុយទៅវិញប្រសិនបើ តុលាការយល់ឃើញថា ភស្តុតាងនោះគ្មានទំនាក់ទំនងជាមួយនឹងអង្គហេតុដែលនឹងត្រូវបញ្ជាក់ និងភស្តុតាង ផ្សេងទៀតដែលមិនចាំបាច់នោះ តុលាការអាចបដិសេធមិនយកមកពិនិត្យបាន[48]។ ជាធម្មតា ការពិនិត្យភស្តុតាងត្រូវធ្វើឡើងក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលធ្វើឡើងជាសាធារណៈប៉ុន្តែ ការពិនិត្យភស្តុតាងជាឯកសារ ត្រូវធ្វើឡើងដោយការអានឯកសារនោះ ដោយចៅក្រម ហេតុដូច្នេះបើប្រៀបធៀបទៅនឹងការការសាកសួរសាក្សី ជាដើម មិនសូវមានទំនាក់ទំនងខ្លាំងនឹងគោលការណ៍បើកជាសាធារណៈទេ ហើយម្យ៉ាងវិញទៀត ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តីឱ្យបានត្រឹមត្រូវ ភាគច្រើនគេត្រូវការភស្តុតាងជាឯកសារ ដែលតុលាការពិនិត្យភស្តុតាងជាឯកសារ ដោយមានកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តី [49]។

**២.១.១.៥.ការបំបែក ឬ ការបញ្ចូលរឿងក្តី**

ក្នុងដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប្រសិនបើតុលាការយល់ឃើញថាចាំបាច់ តុលាការអាចបំបែករឿងក្តីមួយ ទៅជារឿងក្តីផ្សេងៗ ហើយធ្វើការជម្រះក្តីលើរឿងក្តីទាំងនោះ ដោយដាច់ពីគ្នាបានដែលនេះហៅថា ការបំបែកសំណុំរឿងក្តី ។ ឧទាហរណ៍ប្រសិនបើនៅក្នុងបណ្តឹងតែមួយដើមចោទបានទាមទារឱ្យចុងចម្លើយសងប្រាក់កម្ចីផង និង បង់ប្រាក់ថ្លៃលក់ទិញផង តុលាការអាចបំបែកការទាមទារឱ្យបង់ប្រាក់ថ្លៃលក់ទិញចេញពីបណ្តឹងនោះ ហើយធ្វើការជម្រះក្តីដាច់ដោយឡែកបាន ផ្ទុយមកវិញ តុលាការក៏អាចរួមបញ្ចូលរឿងក្តីផ្សេងៗដែលកំពុងចាត់ការនៅក្នុងតុលាការតែមួយ ហើយធ្វើការជំនុំជម្រះក្តីសរុប ដោយនីតិវិធីតែមួយបានផងដែរប្រសិនបើរឿងក្តីទាំងអស់នេះមាននូវខ្លឹមសារពាក់ព័ន្ធគ្នា [50]។ ការបង្គាប់ឱ្យបំបែក ឬ បញ្ចូលរឿងក្តី តុលាការត្រូវធ្វើឡើងដោយដីកាសម្រេច ឬ អាចលុបចោលដីកាសម្រេចនោះបាន ក្នុងករណីតុលាការបានបង្គាប់ ឱ្យបញ្ចូលរឿងក្តីដែលមានភាគីខុសគ្នា នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅពេលភាគីដែលមិនមាន

[46] សេចក្តីពន្យល់អំពី ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ ទំព័រទី៨៤ ៨៥

[47] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ មាត្រា ១២៥ កថាខណ្ឌទី៣

[48] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ មាត្រា ១២៦

[49] សូមមើល សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០៦ ចំណុចទី៣

[50] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ ទំព័រទី ៨៥ ចំណុច ៦

ឱកាសសាកសួរសាក្សី ដោយសាក្សីនោះបានសួររួចហើយមុនពេលបញ្ចូលរឿងក្តី បានដាក់ពាក្យសុំសាកសួរសាក្សីនោះ តុលាការត្រូវសាកសួរសាក្សីនោះ[51]។

**២.១.២.សកម្មភាពរបស់ភាគី**

នៅក្នុងដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ភាគីមានសិទ្ធិ និងករណីកិច្ច បំពេញភារកិច្ច ទៅតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ដោយហេតុថា នៅក្នុងរដ្ឋប្បវេណី ពោលគឺ ភាគីគឺជាប្រធាននៃនីតិវិធីរដ្ឋប្បវេណី ត្រូវធ្វើឡើងដោយកំណត់ជាស្ថាពរ នូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ នៃទំនាក់ទំនងគតិយុត្តកំណត់ណាមួយនៃភាគីទាំងសងខាង ហើយការពារសិទ្ធិរបស់អ្នកដែលមានសិទ្ធិនោះ។ ដូច្នេះហើយភាគីមានករណីកិច្ចស្រាវជ្រាវឱ្យបានលំអិតជាមុន នូវទំនាក់ទំនងនៃអង្គហេតុចំពោះសាក្សី និងភស្តុតាងផ្សេងៗ ដើម្បីធ្វើការអះអាង និង បញ្ជាក់ឱ្យបានគ្រប់គ្រាន់ច្បាស់លាស់[52]។

**២.១.២.១ ការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន**

បន្ទាប់មកពីបានដាក់ពាក្យសុំលើអង្គសេចក្តីនៃរឿងក្តីហើយ ដើមចោទនឹងធ្វើសេចកក្តីថ្លែងការណ៍គាំទ្រពាក្យសុំរបស់ខ្លួន ហើយចុងចម្លើយក៏នឹងធ្វើសេចក្តីថ្លែងការណ៍គាំទ្រពាក្យសុំរបស់ខ្លួនដែរ ។ សេចក្តីថ្លែងការណ៍របស់ដើមចោទ គេហៅថា មធ្យោបាយតទល់ (វិធីតទល់) រីឯសេចក្តីថ្លែងការណ៍របស់ចុងចម្លើយវិញ គេហៅថា មធ្យោបាយការពារខ្លួន (វិធីការពាខ្លួន ) [53]។ មធ្យោបាយតទល់ ឬ ការពារខ្លួន ត្រូវដាក់ឱ្យតុលាការនៅពេលណាមួយដែលសមរម្យ ទៅតាមដំណើរការនៃបណ្តឹង[54] ។ មធ្យោបាយតទល់ ឬការពារខ្លួន អាចនិយាយម្យ៉ាងវិញទៀតថា " ប្រភពជាមូលដ្ឋាននៃសាលក្រម" ក៏បានដែរ រីឯមធ្យោបាយតទល់ ជាអ្វីៗទាំងឡាយដែលដើមចោទដាក់ទៅតុលាការ ដើម្បីយកមកធ្វើជាមូលដ្ឋានសាលក្រមនៃពាក្យសុំរបស់ខ្លួន (ឧ. បណ្តឹង) រីឯមធ្យោបាយការពារខ្លួន គឺជាអ្វីៗទាំងឡាយដែលចុងចម្លើយដាក់ទៅតុលាការ ដើម្បីយកមកធ្វើជាមូលដ្ឋាននៃពាក្យសុំប្រឆាំងវិញ (ឧ. ពាក្យសុំឱ្យលើកចោលបណ្តឹង ពាក្យសុំឱ្យច្រានចោលការទាមទារ )[55]។

**២.១.២.២ ការសុំបញ្ចូលបន្ថែម ឬ ផ្លាស់ប្តូរកម្មវត្ថុបណ្តឹង**

ដើមចោទអាចបន្ថែម ឬ ផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង រហូតដល់ពេលចប់ការទាញហេតុផលដោយផ្ទាល់មាត់បាន លុះត្រាតែមិនមានប្តូរមូលដ្ឋាននៃការទាមទារ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកអនុវត្តឡើយ ចំពោះករណីដែលធ្វើឱ្យនីតិវិធីនៃបណ្តឹងមានការយឺតយ៉ាវខ្លាំងដោយសារការបន្ថែម ឬ ផ្លាស់ប្តូរនោះ ។ ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង ត្រូវធ្វើឡើងជាលាយលក្ខអក្សរ [56]។ ការបន្ថែមកម្មវត្ថុនៃបណ្តឹង គឺដើមចោទរក្សាទុកការ

[51] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ មាត្រា ៩៩

[52] សូមមើល ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ៩២

[53] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ ទំព័រទី ៧៨

[54] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ៩៣

[55] សូមមើលសេចក្តីកំណត់ ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩៣

[56] សូមមើល ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ៨៤ កថាខណ្ឌទី ១ ,២

ទាមទារដើម ហើយបន្ថែមការទាមទារថ្មី ។ ឧទាហរណ៍ ក្នុងបណ្ដឹងទាមទារឱ្យចេញពីផ្ទះ ដោយសារមិនបង់ថ្លៃឈ្នួល ដើមចោទ បន្ថែមទាមទារប្រាក់សំណងការខូចខាតស្មើនឹងថ្លៃឈ្នួល រហូតដល់ពេលអ្នកជួលចេញពីផ្ទះនោះ ។ ការផ្លាស់ប្ដូរ កម្មវត្ថុនៃបណ្ដឹង គឺដើមចោទដកការទាមទារដើម ដោយដាក់ការទាមទារថ្មី ។ ឧទាហរណ៍ ក្នុងបណ្ដឹងទាមទារចេញពីផ្ទះដោយសារមិនបង់ថ្លៃឈ្នួល ប្រសិនបើមានអគ្គិភ័យឆេះអស់ ដោយមានកំហុសរបស់ចុងចម្លើយ នៅពេលតុលាការកំពុងចាត់ការរឿងក្ដីនេះ ដើមចោទផ្លាស់ប្ដូរការទាមទាររបស់ខ្លួនទាំងស្រុងទៅការទាមទារសំណងការខូចខាត ដោយសារការបាត់បង់ផ្ទះ។

**២.១.២.៣ ការធ្វើបណ្ដឹងតប**

ចុងចម្លើយអាចប្ដឹងតប ទៅតុលាការដែលកំពុងចាត់ការបណ្ដឹងដើម រហូតដល់ពេលចប់ការទាញហេតុផលដោយផ្ទាល់មាត់បាន លុះត្រាតែការទាមទារដែលជាកម្មវត្ថុនៃបណ្ដឹងតបនោះទាក់ទងនឹងការទាមទារដែលជាកម្មវត្ថុនៃបណ្ដឹងដើម ឬមធ្យោបាយការពារខ្លួនសម្រាប់បណ្ដឹងដើម ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកអនុវត្តឡើយចំពោះករណីដែលការទាមទារជាកម្មវត្ថុនៃបណ្ដឹងតបនោះ ស្ថិតនៅក្រោមសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការដទៃទៀតតាមច្បាប់ ឬ ករណីដែលការប្ដឹងតបនោះនឹងធ្វើឱ្យមានការយឺតយ៉ាវខ្លាំងក្នុងនីតិវិធីនៃបណ្ដឹង [57]។ បណ្ដឹងតប ជាបណ្ដឹងដែលត្រូវបានធ្វើឡើងដោយភាគីម្ខាងទៀតនៃបណ្ដឹងដើម ។ លក្ខខណ្ឌនៃកា6yរធ្វើបណ្ដឹងតបនេះ គឺលុះត្រាតែការទាមទារដែលជាកម្មវត្ថុនៃបណ្ដឹងតបនោះទាក់ទងនឹងការទាមទារដែលជាកម្មវត្ថុនៃបណ្ដឹងដើម ឬជាមធ្យោបាយការពារខ្លួន ដែលត្រូវធ្វើឡើងសម្រាប់បណ្ដឹងដើមនោះ ។ ឧទាហរណ៍ លោក **ក** បានទាមទារឱ្យ លោក **ខ** ចុះចេញពីផ្ទះខ្លួន ដោយលើកសំអាងថា ផុតអាណត្តិនៃកិច្ចសន្យាជួល ហើយលោក **ខ** ប្ដឹងទាមទារឱ្យបន្តកិច្ចសន្យាជួលដោយលើកហេតុផលថា កិច្ចសន្យាកំណត់ពីសិទ្ធិអាទិភាពរបស់ភាគីអ្នកសុំជួល ក្នុងការបន្តកិច្ចសន្យាជាដើម ។ បណ្ដឹងរបស់ **ខ** ជាបណ្ដឹងតប ។

**២.១.២.៤ ការស្នើសុំឱ្យភាគីម្ខាងទៀតដាក់ឯកសារ**

ការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ត្រូវធ្វើឡើងយដោយការផ្ដល់ឯកសារដែលសាមីភាគីមាន ឬដោយដាក់ពាក្យសុំទៅតុលាការឱ្យបង្គាប់ម្ចាស់ដើមផ្ដល់ឯកសារនោះមក[58]។ ពាក្យសុំដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារ ត្រូវធ្វើឡើងដោយបញ្ជាក់ឱ្យបានច្បាស់លាស់[59]។

**២.១.២.៥ ការស្នើសុំឱ្យតុលាការពិនិត្យភស្តុតាង**

ជាគោលការណ៍ការពិនិត្យភស្តុតាង ត្រូវធ្វើឡើងតាមការស្នើសុំឱ្យពិនិត្យរបស់ភាគី[60]។ ចំពោះភស្តុតាងដែលអាចទទួលមកពិនិត្យក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន គឺមានតែភស្តុតាងជាឯកសារ

---

[57] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ មាត្រា មាត្រា ៨៦

[58] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ មាត្រា មាត្រា ១៤៨ កថាខណ្ឌទី ១

[59] សូមមើល ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ មាត្រា មាត្រា១៥១

[60] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ មាត្រា ១២៤ កថខណ្ឌទី ១ នៃ

ក្នុងកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទ និងភស្តុតាង[61]។ តុលាការត្រូវចាំបាច់ធ្វើការពិនិត្យលើឯកសារដែលភាគីបានដាក់ ហើយការពិនិត្យភស្តុតាងជាឯកសារនេះ ដែលត្រូវធ្វើឡើងដោយការផ្តល់នូវឯកសារដែលសាមីភាគីមាន ឬ ដោយដាក់ពាក្យសុំទៅតុលាការឱ្យបង្គាប់ឱ្យម្ចាស់ឯកសារផ្ញើឯកសារនោះមក[62]។ ហេតុនេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណី អនុញ្ញាតអាចធ្វើការពិនិត្យភស្តុតាងជាឯកសារ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានត្រឹមកម្រិតដែលចាំបាច់ដើម្បីរៀបចំ ចំណុចវិវាទ[63]។ ការស្នើសុំឱ្យពិនិត្យភស្តុតាង ក៏អាចធ្វើមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ មុនកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់បានដែរ [64] ។ ចំពោះភស្តុតាងដែលតុលាការ យកមកពិនិត្យគឺត្រូវតែជាភស្តុតាង ដែលជាឯកសារដែលចាំបាច់ ហើយមានទំនាក់ទំនងជាមួយអង្គហេតុ ប៉ុន្តែសម្រាប់ភស្តុតាងដែលជាសាក្សី គឺត្រូវដាក់ស្នើសុំទៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់វិញ ។ ផ្ទុយទៅវិញប្រសិនបើ តុលាការយល់ឃើញថា ភស្តុតាងនោះគ្មានទំនាក់ទំនងជាមួយនឹងអង្គហេតុដែលនឹងត្រូវបញ្ជាក់ និងភស្តុតាង ផ្សេងទៀតដែលមិនចាំបាច់នោះ តុលាការអាចបដិសេធមិនយកមកពិនិត្យបាន [65]។

### ២.១.៣ សកម្មភាពរបស់ក្រឡាបញ្ជី

នៅគ្រប់អង្គការតុលាការ និងអង្គការអយ្យការគ្រប់ជាន់ថ្នាក់ មានក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាលព្រមទាំងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ជាជំនួយចាំបាច់[66]។ ក្រឡាបញ្ជី គឺជាអ្នកបច្ចេកទេសផ្នែកនីតិវិធីដែលជួយសម្រួលដល់ចៅក្រម និងព្រះរាជអាជ្ញានៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ និងអយ្យការក្នុងសកម្មភាពជម្រះក្តីទៅតាមលក្ខខណ្ឌដែលមានកំណត់ក្នុងច្បាប់ ។ ជារួមក្រឡាបញ្ជី គឺជាលេខាធិការផ្ទាល់របស់ចៅក្រម និងព្រះរាជអាជ្ញា ក្នុងការជួយសម្រួលការងារបច្ចេកទេសផ្នែកនីតិវិធីដែលច្បាប់តម្រូវត្រូវតែមាន ។ ជាក់ស្តែងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់ តុលាការត្រូវឱ្យក្រឡាបញ្ជី ធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅគ្រប់កាលបរិច្ឆេទនីមួយៗ។ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងក្រឡាបញ្ជី ត្រូវចុះហត្ថលេខាលើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការត្រៀមហេតុផល[67]។

[61] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ មាត្រា ១០៦

[62] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ១២៨ កថាខណ្ឌទី១

[63] សេចក្តីពន្យល់អំពី ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ ទំព័រទី៨៤ ៨៥

[64] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ១២៥ កថាខណ្ឌទី៣

[65] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ មាត្រា ១២៦

[66] ច្បាប់ស្តីពីរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ កថាខណ្ឌទី១ មាត្រា ៩

[67] សូមមើល ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ មាត្រា ១០៩ និង កថាខណ្ឌទី ២ នៃមាត្រា ១១០

### ២.១.៣.១ ការធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

តុលាការត្រូវបង្គាប់ឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុ នៅរាល់កាលបរិច្ឆេទនីមួយៗនៃនីតិវិធីត្រៀម សម្រាប់ការទាញហេតុផល[៦៨]។ នៅក្នុងកំណត់ហេតុនោះ ក្រឡាបញ្ជីត្រូវកត់ត្រានូវចំនុចនានា ដែលមានចែង ក្នុងមាត្រា១១០ និងមាត្រា១១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ចៅក្រម ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ក្នុងករណីដែលត្រូវជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះ និងក្រឡាបញ្ជីត្រូវចុះហត្ថលេខាលើកំណត់ហេតុនោះ ។

នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រានូវចំណុចក្បាលកំណត់ហេតុ និងខ្លឹមសារ និងការចុះនិទ្ទេសដូចខាងក្រោម ៖

- សញ្ញាណរឿងក្តី
- ឈ្មោះចៅក្រម និង ក្រឡាបញ្ជី
- ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និង អ្នកបកប្រែដែលបានបង្ហាញខ្លួន
- ពេលវេលា និង ទីកន្លែង ។

នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ទាញហេតុផល ត្រូវកត់ត្រានូវសេចក្តីសង្ខេបអំពីសកម្មភាពដែលបានធ្វើឡើងនៅកាលបរិច្ឆេទនីមួយៗ ហើយ ជាពិសេស ត្រូវកត់ត្រាឱ្យបានច្បាស់លាស់នូវចំណុចខាងក្រោមនេះ៖

- ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និង ចម្លើយតបរបស់ចុងចម្លើយចំពោះការទាមទារនោះ ។
- ខ្លឹមសារនៃអង្គហេតុដែលបានអះអាង និង ការស្នើសុំឱ្យពិនិត្យភស្តុតាង
- ការទទួលស្គាល់ ឬ មិនទទួលស្គាល់របស់ភាគី ចំពោះអង្គហេតុដែលបានអះអាងដោយភាគីម្ខាងទៀត និងការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះភាគីត្រឹមត្រូវនៃឯកសារ។
- ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ និង ការទទួលស្គាល់ការទាមទារ។
- ចំណុចដែលតុលាការបានបង្គាប់ឱ្យកត់ត្រា និង ចំណុចដែលតុលាការអនុញ្ញាតឱ្យកត់ត្រា តាម ការទាមទាររបស់ភាគី
- ការសម្រេចសេចក្តីដែលបានធ្វើឡើងនៅកាលបរិច្ឆេទនោះ ដោយមិនធ្វើជាលាយល័ក្ខណ៍អក្សរ។

### ២.១.៣.២ កិច្ចការបញ្ជូននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីនៃបណ្តឹងក្រោយពីតុលាការពិនិត្យឃើញថាបណ្តឹងមានលក្ខណៈត្រឹមត្រូវ ក៏ដូចជាបានកំណត់កាលបរិច្ឆេទ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលរួចរាល់ហើយតុលាការត្រូវធ្វើការ កោះហៅភាគីទាំងសងខាង ដែលជាគោលការណ៍បញ្ជូន ត្រូវធ្វើឡើងដោយឆន្ទានុសិទ្ធិ លើកលែងតែមានបញ្ញត្តិច្បាប់ពិសេស។ កិច្ចការបញ្ជូនត្រូវធ្វើឡើងដោយក្រឡាបញ្ជី ដោយការបញ្ជូនបានប្រតិបត្តិដោយបុគ្គលិក ប្រៃសណីយ៍ អាជ្ញា

---

[៦៨] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ មាត្រា ១០៩

សាលា ឬ ក្រឡាបញ្ជី [69]។ ក្នុងនោះឃើញថា ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល កិច្ចការបញ្ជូនរបស់ក្រឡាបញ្ជី ដូចជា ផ្ញើការបញ្ជូនពាក្យបណ្តឹងទៅឲ្យភាគីចុងចម្លើយ[70] ចំពោះការកោះតាមកាលបរិច្ឆេទ ត្រូវធ្វើដោយបញ្ជូនដីកាកោះ ឬ ដោយជូនដំណឹងអំពីកាលបរិច្ឆេទ ទៅអ្នកដែលបានបង្ហាញខ្លួននៅតុលាការចំពោះបណ្តឹងដែលពាក់ព័ន្ធ[71]។ ការបន្ថែម ឬការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ។ ឯកសារដែល បន្ថែម ឬការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង ត្រូវបញ្ជូនទៅភាគីម្ខាងទៀត បើតុលាការយល់ឃើញថាការបន្ថែម ឬផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹងនោះត្រឹមត្រូវ[72]។ ការដកពាក្យបណ្តឹង ត្រូវធ្វើជាលាយលក្ខអក្សរ តុលាការត្រូវបញ្ជូនលិខិតនេះទៅចុងចម្លើយ ហើយប្រសិនបើដកពាក្យបណ្តឹង ត្រូវបានធ្វើឡើងដោយផ្ទាល់មាត់នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬកាលបរិច្ឆេទនៃការផ្សះផ្សា តុលាការត្រូវបញ្ជូនឯកសារចម្លងនៃកំណត់ហេតុនៃកាលបរិច្ឆេទនេះ ទៅចុងចម្លើយ[73]។

## ២.២ ការសម្រេច និងបណ្តឹងឧបាស្រ័យ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ជាគោលការណ៍ ក្នុងការដឹកនាំនីតិវិធីនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជាសិទ្ធិអំណាចរបស់តុលាការ ហើយត្រូវអនុវត្តដោយតុលាការ[74]។ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការអាចចេញដីកាសម្រេចដែលទាក់ទងនឹងការស្នើសុំឱ្យពិនិត្យ ឬ ដីកាសម្រេចផ្សេងទៀតដែលអាចសម្រេចបាន ក្រៅពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ និង អាចពិនិត្យភស្តុតាងជាឯកសារ ដោយមានកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តី និងភស្តុតាង [75]។

ក្នុងករណីដែលភាគីយល់ឃើញថា ផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ត្រូវបានបំពានដោយសារការដឹកនាំនីតិវិធីនៃបណ្តឹង របស់តុលាការ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ដោយសារការអនុវត្តសិទ្ធិឱ្យបំភ្លឺ របស់តុលាការ ដែលមានចែងក្នុងមាត្រា ៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគីអាចប្តឹងតវ៉ាចំពោះការដឹកនាំនីតិវិធីនោះបាន ។ ក្នុងករណីដែលមានការប្តឹងតវ៉ាបែបនេះកើតឡើង តុលាការត្រូវសម្រេចសេចក្តីចំពោះបណ្តឹងតវ៉ានេះ ដោយដីកាសម្រេច[76]។

[69] សូមមើលមាត្រា ២៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី
[70] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ៧៩
[71] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ មាត្រា ២៤២
[72] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ កថាខណ្ឌទី១,២,៣,៤ មាត្រា ៨៤
[73] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ កថាខណ្ឌទី៤ នៃមាត្រា ២១៧
[74] សូមមើល ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ៩០ , មាត្រា ៩៤ , មាត្រា ៩៩ និង មាត្រា ១០០ ជាអាទិ៍
[75] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ១០៦
[76] សេចក្តីពន្យល់ អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ ៖នីតិវិធីបណ្តឹង ទំព័រ ៦៤

### ២.២.១ ការសម្រេចរបស់តុលាការ

#### ២.២.១.១. ដីកាសម្រេច

ក្នុងចំណោមសេចក្តីសម្រេចរបស់ស្ថាប័នតុលាការ ក្រៅពីសាលក្រម ឬ សាលដីកា មានដីកាសម្រេច។ ដីកាសម្រេច គឺជាសេចក្តីសម្រេចរបស់តុលាការ ឬ ចៅក្រម ដែលអាចធ្វើបានដោយមិនចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់[77]។ ដីកាសម្រេចដែលធ្វើដោយចៅក្រម សំដៅលើដីកាសម្រេចរបស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ក្នុងករណីដែលតុលាការជំនុំជម្រះរឿងក្តីដោយក្រុមប្រឹក្សា [78]។

ដីកាសម្រេច គឺជាសេចក្តីសម្រេចដែលអាចធ្វើដោយផ្ទាល់មាត់ក៏បាន ធ្វើជាលាយលក្ខណ៍អក្សរក៏បាន។ ការអះអាងបែបនេះ គឺផ្អែកទៅលើការបកស្រាយក្នុងក្រមនីតិវិធីរដ្ឋប្បវេណី[79] ដែលចែងថា ក្នុងករណីចេញ ដីកាសម្រេចជាលាយលក្ខណ៍អក្សរ។ ការប្រើពាក្យបែបនេះ អាចឲ្យយើងសន្និដ្ឋានបានថា ដីកាសម្រេចខ្លះក៏អាចធ្វើដោយផ្ទាល់មាត់បានដែរ ។ ប្រសិនបើ ដីកាសម្រេចធ្វើដោយផ្ទាល់មាត់ ដីកាសម្រេចនេះត្រូវកត់ត្រានៅក្នុងកំណត់ហេតុ ដើម្បីទុកជាបន្ទាល់បញ្ជាក់ទៅថ្ងៃក្រោយ។

ជាក់ស្តែង ច្បាប់ (ការសម្រេចសេចក្តីដែលបានធ្វើនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយមិនធ្វើជាលាយលក្ខណ៍អក្សរ)[80] ត្រូវឲ្យកត់ត្រា នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់នូវសេចក្តីសម្រេចដែលបានធ្វើឡើងដោយមិនបានធ្វើជាលាយលក្ខណ៍អក្សរ។ សេចក្តីសម្រេចនេះគឺ មិនមានអ្វីក្រៅពីដីកាសម្រេច (វាមិនមែនជាសាលក្រម) នោះទេ ព្រោះថាសេចក្តីសម្រេចដែលមិនមែនជាសាលក្រម គឺជាដីកាសម្រេច ។

ការធ្វើដីកាសម្រេចជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់គឺវាអាស្រ័យទៅតាមករណីនីមួយៗតាមការយល់ឃើញរបស់ចៅក្រម ឬ ច្បាប់តម្រូវឲ្យធ្វើជាលាយលក្ខណ៍អក្សរ ដូចដីកាសម្រេចដាស់តឿនជាអាទិ៍[81]។ ក្នុងករណីដែលច្បាប់ពុំបានកំណត់ចំពោះដីកាសម្រេចដែលត្រូវធ្វើដោយផ្ទាល់មាត់ ឬ លាយលក្ខណ៍អក្សរទេ ហេតុនេះចៅក្រម ឬ តុលាការអាចចេញដីការសម្រេចជាលាយលក្ខណ៍អក្សរក៏បាន ដោយផ្ទាល់មាត់ក៏បាន ។ ប៉ុន្តែក្នុងករណីមួយចំនួនដោយផ្អែកទៅលើស្ថានភាពនៃការអនុវត្តជាក់ស្តែង យើងប្រហែលជាមិនឃើញដីកាសម្រេចធ្វើដោយផ្ទាល់មាត់បានទេដូចជាករណីនៃដីកាសម្រេចចេញដោយប្រធានតុលាការ ដើម្បីកំណត់ការបែងចែករឿងក្តីជារៀងរាល់មួយឆ្នាំម្តង។ ត្រង់ចំណុចនេះក៏បង្ហាញឲ្យឃើញភាពខុសប្លែកគ្នាជាមួយនឹងសាលក្រម ដែល

---

[77] សូមលើ ក្រមនីតិវិធីរដ្ឋប្បវេនី ឆ្នាំ២០០៦ មាត្រា១៧៩ កថាខណ្ឌទី២ និង មាត្រា ១១៤ កថាខណ្ឌទី១

[78] សូមមើល ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ មាត្រា ៨៩

[79] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ២១៣ កថាខណ្ឌទី២

[80] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ១១១ ចំណុច ច និងមាត្រា ១១៩ ចំណុច ច

[81] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ៣២៤

ដាច់ខាតត្រូវចេញជាលាយលក្ខណ៍អក្សរ[82] ចំណែកឯ ដីកាសម្រេចវិញ គឺជាសេចក្តីសម្រេចរបស់តុលាការ ឬ ចៅក្រមដែលមានគោលបំណងដើម្បីចាត់ការលើការដឹកនាំនីតិវិធីនៃបណ្តឹង។

**ឧទាហរណ៍ ៖** ដីកាសម្រេចទាក់ទងនឹងបណ្តឹងជិតចិត្ត ដីកាសម្រេចឲ្យជំនុំជម្រះក្តីដោយក្រុមប្រឹក្សាជំនុះជម្រះជាដើម។ ឬ ក្នុងគោលបំណងដើម្បីចាត់ចែងចំណុចបន្ទាប់បន្សំក្នុងការវិនិច្ឆ័យបណ្តឹងប៉ុណ្ណោះ។

**ឧទាហរណ៍៖** ដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួន ដីកាសម្រេចទាក់ទងនឹងការស្នើសុំឲ្យពិនិត្យភស្តុតាងជាដើម។

ជាគោលការណ៍ ការចេញដីកាសម្រេចមិនចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ទេ ព្រោះថា ដីកាសម្រេច សម្រេចតែអំពីចំណុចបន្ទាប់បន្សំនៃនីតិវិធីប៉ុណ្ណោះ។ ច្បាប់បានទុកលទ្ធភាពឲ្យចៅក្រមសម្រេចថាតើត្រូវឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ឬ អត់ ដោយយោងទៅតាមករណីនីមួយៗហើយ ទោះបីជាមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ក៏ដោយ តុលាការអាចសួរភាគីបានពោលគឺតុលាការផ្តល់ឱកាសឲ្យភាគីធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរទាក់ទិននឹងចំណុចដែលត្រូវសម្រេចដោយដីកាសម្រេច [83]។ ផ្ទុយទៅវិញ ជាគោលការណ៍សាលក្រមត្រូវសម្រេចដោយឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែករណីពិសេសដែលមានបញ្ញត្តិក្នុងច្បាប់[84]។

### ២.២.១.២.អានុភាពនៃដីកាសម្រេច

ដីកាសម្រេចនឹងមានអានុភាព លុះត្រាតែបានជូនដំណឹងតាមវិធីដែលទទួលស្គាល់ថាសមរម្យ[85]។ ហេតុនេះ ចំពោះដីកាសម្រេចធ្វើដោយផ្ទាល់មាត់ចំពោះមុខភាគីដីកាសម្រេចនឹងបង្កើតអានុភាពអនុវត្តភ្លាម នៅពេលតុលាការ ឬ ចៅក្រមបានសម្រេចសេចក្តីដោយដីកាសម្រេចនោះ ។ ចំពោះដីកាសម្រេចដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរចៅក្រមត្រូវចុះហត្ថលេខា ហើយជូនដំណឹងពីដីកាសម្រេចនោះទៅដល់អ្នកពាក់ព័ន្ធហើយ មានអានុភាពភ្លាមៗតែម្តង លើកលែងតែករណីផ្សេងកំណត់ដោយច្បាប់។

ឧទាហរណ៍៖ ចំពោះដីកាសម្រេចដាស់តឿន[86] កំណត់ថាដីកាសម្រេចដាស់តឿនត្រូវមានអានុភាព នៅពេលដែលបានបញ្ជូនទៅដល់កូនបំណុល។

ក្រៅពីនីតិវិធីបញ្ជូន វិធីជូនដំណឹងដីកាសម្រេចអាចធ្វើបានតាមគ្រប់រូបភាពផ្សេងទៀត ដែលទទួលស្គាល់ថាសមរម្យ។ ក្នុងន័យនេះ ការជូនដំណឹងអំពីដីកាសម្រេច អាចធ្វើដោយផ្ទាល់មាត់នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ អាចធ្វើតាមរយៈទូរស័ព្ទ ឬ ទូរសារជាដើម។ ដើម្បីជាតឹកតាងនៃកាជូនដំណឹង ក្នុង

[82] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ១៨៩
[83] សូមមើល ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ១១៤
[84] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ៨១
[85] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ២១៣ កថាខណ្ឌទី១
[86] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ៣២៥

ច្បាប់[87] តម្រូវឲ្យក្រឡាបញ្ជីបញ្ជាក់ឲ្យបានច្បាស់លាស់នូវហេតុការណ៍ និង វិធីនៃការជូនដំណឹងដាក់នៅក្នុងសំណុំរឿង។ ផ្ទុយពីដីកាសម្រេច សាលក្រមនឹងមានអានុភាពដោយការប្រកាស[88] ហើយតុលាការអាចប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្នបាន។ ដោយមូលហេតុថា ដីកាសម្រេចមានអានុភាព អនុវត្តភ្លាមៗក្រោយការជូនដំណឹង ដូច្នេះការប្រកាសឲ្យមានការអនុវត្តជាបណ្ដោះអាសន្នដែលអនុវត្តសម្រាប់សាលក្រម ក៏ពុំមានអានុភាពសម្រាប់ដីកាសម្រេចឡើយ ។

ដីកាសម្រេចដែលមានគោលដៅត្រឹមតែដឹកនាំនីតិវិធីនៃបណ្ដឹង អាចលុបចោលនាពេលណាក៏បាន[89] ដោយហេតុថា ដីកាសម្រេចមានពីរប្រភេទគឺ ដីកាដែលមានគោលបំណង ចាត់ការលើការដឹកនាំនីតិវិធីនៃបណ្ដឹង និង ដីកាដែលមានគោលបំណងដើម្បីចាត់ចែងចំណុចបន្ទាប់បន្សំក្នុងការវិនិច្ឆ័យបណ្ដឹង។ ហេតុនេះតាមការបកស្រាយដែលមានលក្ខណៈផ្ទុយមកវិញមានន័យថា មានតែដីកាសម្រេចដែលមានគោលដៅដឹកនាំនីតិវិធីនៃបណ្ដឹងប៉ុណ្ណោះដែលអាចលុបចោល ពេលណាក៏បាន ចំណែកឯដីកាសម្រេចផ្សេងទៀតក្រៅពីដីកានេះ ។

**ឧទាហរណ៍៖** ប្រសិនបើ តុលាការយល់ឃើញថា ការបង្គាប់ឲ្យដាក់ឯកសារត្រៀម ក្នុងអំឡុងពេលណាមួយមានលក្ខណៈមិនសមរម្យដោយហេតុពេលវេលាខ្លីពេក ឬក៏មានការស្នើសុំអំពីការពន្យាពេលរបស់ភាគីដោយមានមូលហេតុសមរម្យ តុលាការអាចលុបចោលដីកាសម្រេចនេះវិញបាន។ រីឯសាលក្រមវិញគឺ សុទ្ធតែមានអត្តពន្ធភាព[90]។

មួយវិញទៀត ក្នុងច្បាប់[91] បានកំណត់ករណីបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមដែលចំណុចនេះមិនអាចយកមកអនុវត្តបានសម្រាប់រាល់ដីកាសម្រេចទាំងអស់នោះទេ។

**ឧទាហរណ៍៖** ដីកាសម្រេចអំពីពាក្យសុំពិនិត្យភស្តុតាង មានអានុភាពសម្រាប់តែភាគីពាក់ព័ន្ធប៉ុណ្ណោះ។

### ២.២.១.៣ ការផ្ទេរសមត្ថកិច្ចតុលាការ

នៅក្នុងករណីដែលមានចាត់ចែងបណ្ដឹងខុសសមត្ថកិច្ចសាលាជម្រះក្ដី ដោយតុលាការយល់ឃើញថា បណ្ដឹងទាំងមូល ឬ ផ្នែកណាមួយមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេ តុលាការនេះត្រូវផ្ទេរបណ្ដឹងទៅតុលាការដែលមានសមត្ថកិច្ច ។ ពាក្យសុំផ្ទេរបណ្ដឹងត្រូវធ្វើជាលាយលក្ខណ៍អក្សរ លើកលែងតែករណីដែលដាក់ពាក្យសុំនៅកាលបរិច្ឆេទ ។ មួយវិញទៀត នៅពេលពាក្យសុំនេះ ត្រូវបញ្ជាក់ឲ្យច្បាស់លាស់អំពីមូលហេតុនៃពាក្យសុំនោះ ។

បើតុលាការ យល់ឃើញថាចាំបាច់ដើម្បីជៀសវាងពីការយឺតយ៉ាវហួសហេតុនៃនីតិវិធី ឬ ដើម្បីឲ្យមានសមធម៌រវាងគូភាគី ដោយពិចារណាអំពីលំនៅឋានរបស់ភាគី និងសាក្សីដែលត្រូវសាកសួរ ទីតាំងវត្ថុដែលនឹងត្រូវបាន

[87] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ២១៣ កថាខណ្ឌទី៣
[88] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ១៨៦
[89] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ២១៤
[90] អត្តពន្ធភាពនៃសាលក្រម មានន័យថា សាលក្រមមានអានុភាពចងតុលាការដែលបានប្រកាសសាលក្រម ដោយតុលាការមិនអាចលុបចោលបាន ឬ កែប្រែសាលក្រមនេះបានឡើយ លើកលែងតែករណីនៃដីកាសម្រេចកែតម្រូវ។
[91] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ១៩៨

ត្រួតពិនិត្យ និងកាលៈទេសៈផ្សេងៗទៀត ដែលក្នុងនោះតុលាការនោះអាចផ្ទេរបណ្ដឹងទាំងមូល ឬ ផ្នែកណាមួយទៅឲ្យតុលាការផ្សេងទៀតដែលមានសមត្ថកិច្ច។ ប៉ុន្តែតុលាកាអាចសួរយោបល់របស់គូភាគីបាន ដើម្បីធ្វើការសម្រេចផ្ទេរសមត្ថកិច្ច ។ យ៉ាងណាមិញ ទោះបីតុលាការអាចផ្ទេរសមត្ថកិច្ចដើម្បីជៀសវាងការយឺតយ៉ាវក៏ដោយ វាក៏មិនអាចយកមកអនុវត្តបានឡើយ ចំពោះករណីដែលបណ្ដឹងស្ថិតក្រោមសមត្ថកិច្ចផ្ដាច់មុខដែលបានកំណត់ដោយច្បាប់របស់តុលាការដែលចាត់ការបណ្ដឹងនោះ ។

**២.២.១.៤.ការដកហូតសមត្ថកិច្ចជំនុំជម្រះ**

ការដកហូតសមត្ថកិច្ចជំនុំជម្រះ គឺជា របៀបមួយដែលដកចៅក្រមពីការបំពេញមុខងារដោយស្វ័យប្រវត្តិតាមច្បាប់ ក្នុងករណីដែលមានហេតុដែលប៉ះពាល់ដល់សមភាពដោយធ្ងន់ធ្ងរ ។ ករណីដែលអាចធ្វើការដកហូតសមត្ថកិច្ចបានមានដូចជា៖

- ចៅក្រម ឬសហព័ទ្ធរបស់ចៅក្រម ឬអតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្ដី
- ចៅក្រមជាញាតិលោហិតក្នុងថ្នាក់ទី៦ ឬញាតិពន្ធក្នុងថ្នាក់ទី៣ ឬអតីតញាតិពន្ធក្នុងថ្នាក់ទី៣របស់ភាគីណាមួយ
- ចៅក្រមដែលទទួលបន្ទុករឿងក្ដីធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ
- ចៅក្រមបានធ្វើសាក្សី ឬធ្វើជាអ្នកតំណាង ឬជាអ្នកជំនួយឲ្យភាគីចំពោះរឿងក្ដី ។

**២.២.២ ការប្ដឹងឧបាស្រ័យ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

ករណីដែលភាគីយល់ឃើញថា ផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ត្រូវបានបំពេញដោយសារដឹកនាំនីតិវិធីនៃបណ្ដឹង របស់តុលាការ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចជានៅក្នុងនីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់ ឬ ដោយសារការអនុវត្តសិទ្ធិឱ្យបំភ្លឺ របស់តុលាការ ភាគីអាចប្ដឹងតវ៉ាបាន [92]។ បណ្ដឹងឧបា-ស្រ័យ គឺជាបណ្ដឹងរបស់ភាគីដែលពុំយល់ស្រប ជាមួយសេចក្ដីសម្រេចណាមួយ (សាលក្រម សាលដីកា ដីកាសម្រេច ) របស់ចៅក្រម ឬ តុលាការ ដើម្បីទាមទារឱ្យលុបចោល ឬផ្លាស់ប្ដូរសេចក្ដីសម្រេចដើម ។ បណ្ដឹងឧបាស្រ័យក្នុងនីតិវិធីទូទៅត្រូវបានចែងចែកជាពីរ គឺ បណ្ដឹងឧបាស្រ័យទៅតុលាការដដែល និង បណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់[93]។ បណ្ដឹងឧបាស្រ័យ ជាការប្ដឹងរបស់ភាគីដែលតវ៉ាទៅលើសេចក្ដីសម្រេចរបស់តុលាការ ដែលមានក្នុងក្រមនីតិវិធីរដ្ឋប្បវេណី បានបែងចែងចំពោះបណ្ដឹងឧបាស្រ័យនៅក្នុងនីតិវិធីទូទៅ បណ្ដឹងឧបាស្រ័យនីតិវិធីចាត់ចែងរក្សាការពារ និងបណ្ដឹងឧបាស្រ័យនីតិវិធីអនុវត្តបង្ខំ ។ ប៉ុន្តែនៅទីនេះ បណ្ដឹងឧបាស្រ័យក្នុងនីតិវិធីទូទៅនៃនីតិវិធីបណ្ដឹង ដែលសំដៅលើការបណ្ដឹងរបស់ភាគីដែលធ្វើឡើងនៅក្នុងនីតិវិធីវិធីត្រៀមសម្រាប់ការទាញហេតុផល ។

[92] សូមមើល សេចក្ដីពន្យល់ អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ ៖ នីតិវិធីបណ្ដឹង ទំព័រ ៦៤

[93] បណ្ដឹងឧប្រាស្រ័យក្នុងនីតិវិធីរដ្ឋប្បវេណី លោកគ្រូ សេង នាង ចៅក្រមតុលាការកំពូល

### ២.២.២.១ ការប្តឹងតវ៉ាចំពោះការដឹកនាំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

បណ្តឹងតវ៉ានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ពោលគឺភាគីអាចប្តឹងតវ៉ាចំពោះការដឹកនាំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការប្តឹងតវ៉ាចំពោះសកម្មភាពផ្ទុយពីនីតិវិធីបណ្តឹង ។ នីតិវិធីនៃបណ្តឹង ភាគីអាចប្តឹងតវ៉ាចំពោះការដឹកនាំការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការចាត់ចែងរបស់តុលាការ[94] ។ ពោលគឺភាគីមានសិទ្ធិទាមទារឱ្យតុលាការពិនិត្យម្តងទៀត អំពីការដឹកនាំរបស់ក្រុមប្រឹក្សាជំនុំជម្រះ ឬ ចៅក្រមទទួលបន្ទុករឿងក្តី ។ បណ្តឹងតវ៉ាចំពោះការដឹកនាំរបស់ក្រុមប្រឹក្សាជំនុំជម្រះ ត្រូវបានសម្រេចដោយដីកាសម្រេចដោយក្រុមប្រឹក្សានោះ រីឯបណ្តឹងតវ៉ាចំពោះការដឹកនាំរបស់ចៅក្រមទទួលបន្ទុករឿងក្តីតែមួយនាក់ ត្រូវសម្រេចដោយដីកាសម្រេច ដោយចៅក្រមនោះ ។

ក្នុងករណីដែលភាគីម្ខាង ឬ តុលាការបានធ្វើសកម្មភាពបណ្តឹងណាមួយដែលផ្ទុយពីបញ្ញត្តិអំពីនីតិវិធីនៃបណ្តឹង ភាគីអាចប្តឹងតវ៉ាចំពោះសកម្មភាពនោះទៅតុលាការ ហើយអាចអះអាងអំពីមោឃភាពនៃសកម្មភាពនោះបាន ។ ប៉ុន្តែភាគីបានដឹង ឬ អាចដឹងអំពីខុសច្បាប់ហើយមិនបានធ្វើការប្តឹងតវ៉ានៅពេលសមរម្យទេ ភាគីនោះត្រូវបាត់បង់សិទ្ធិប្តឹងតវ៉ា លើកលែងតែករណីដែលមិនអាចបោះបង់សិទ្ធិនេះបាន [95]។ ភាគីដែលអាចប្តឹងតវ៉ា តែមិនបានប្តឹងតវ៉ា ហើយនៅតែឱ្យប្តឹងតវ៉ាបាននៅពេលក្រោយ នោះអាចបះពាល់ដល់ស្ថេរភាពនៃនីតិវិធីបណ្តឹង ហើយផ្ទុយនឹងផលប្រយោជន៍សេដ្ឋកិច្ចក្នុងនីតិវិធី ប៉ុន្តែបើក្នុងករណីដែលភាពខុសច្បាប់នេះផ្ទុយបញ្ញត្តិបង្ខំ ដែលទាក់ទាងយ៉ាងខ្លាំងទៅនឹងផលប្រយោជន៍សាធារណៈ ទោះបីជាមានការយឺតយ៉ាវក្នុងការតវ៉ាក៏ដោយ ក៏មិនបាត់បង់នូវសិទ្ធិតវ៉ាដែរ (ឧ. រចនាសម្ព័ន្ធនៃតុលាការ ការដកហូតចៅក្រម និងសមត្ថកិច្ច ជាដើម ) ។

### ២.២.២.២ ប្តឹងតវ៉ាចំពោះកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ក្នុងករណីដែលភាគី ឬ អ្នកដទៃទៀតដែលពាក់ព័ន្ធ ប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រានៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះ ត្រូវកត់សេចក្តីប្តឹងតវ៉ានេះ នៅក្នុងកំណត់ហេតុនោះ ។ ភាពត្រឹមត្រូវក្នុងការអនុវត្ត និងរបៀបធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចបញ្ជាក់បាន ដោយកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តែមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលកំណត់ហេតុនេះបានបាត់ ឬ បានវិនាស[96]។ នៅពេលតវ៉ាអំពីកំណត់ហេតុ ប្រសិនបើក្រឡាបញ្ជីយល់ឃើញថា ការតវ៉ានេះត្រឹមត្រូវ ឬ ចៅក្រមយល់ឃើញថា ការតវ៉ានេះមានមូលហេតុត្រឹមត្រូវ តុលាការបង្គាប់ឱ្យក្រឡាបញ្ជីកែតម្រូវនោះក្រឡាបញ្ជីត្រូវតែកែតម្រូវ ។ ហើយបើយល់ឃើញថា ការតវ៉ានោះមិនមិនមានមូលហេតុត្រឹមត្រូវនោះទេក្រឡាបញ្ជីត្រូវកត់ត្រាសេចក្តីតវ៉ានៅក្នុងកំណត់ហេតុ ។

---

[94] សូម មើលក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៦ មាត្រា ៩១ កថាខណ្ឌទី១

[95] សូម មើលក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៦ មាត្រា ៩៨

[96] សូមមើល ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ១១២

### ២.២.២.៣ ការប្តឹងជំទាស់ដិតចិត្ត

ក្នុងករណីដែលមានកាលៈទេសៈដែលបណ្តាលឱ្យមានការលំអៀងក្នុងការជម្រះក្តី ចំពោះចៅក្រមណាម្នាក់ នោះភាគីអាចប្តឹងជំទាស់ដិតចិត្តចៅក្រមនោះបាន ។ ប៉ុន្តែក្នុងករណីដែលភាគីបានឆ្លើយទាញហេតុផលចំពោះមុខចៅក្រម ឬ បានធ្វើសេចក្តីដោះសារនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចំពោះចៅក្រមរួចហើយ នោះភាគីមិនអាចប្តឹងជំទាស់ដិតចិត្តចៅក្រមនោះបានឡើយ លើកលែងតែចំពោះករណីភាគីនោះមិនដឹងអំពីមូលហេតុដែលអាចប្តឹងជំទាស់ដិតចិត្ត ឬ ករណីដែលមូលហេតុនៃបណ្តឹងជំទាស់ដិតចិត្តបានកើតឡើងនៅពេលក្រោយ[97]។ អំពីបណ្តឹងជំទាស់ដិតចិត្តចៅក្រមមិនឱ្យអនុវត្តមុខងាររបស់ខ្លួន ក្នុងករណីដែលមាន "កាលៈទេសៈដែលបណ្តាលឱ្យមានការលំអៀងក្នុងការជម្រះក្តី" ទោះបីជាគ្មានមូលហេតុដែលបានកំណត់ក្នុងមាត្រា២៧ (ការដកហូតចៅក្រមពីសមត្ថកិច្ចជម្រះ) ក៏ដោយ ។ យើងមិនអាចរៀបរាប់មូលហេតុនៃការដកហូតទាំងអស់បានទេ ហេតុដូច្នេះដើម្បីបំពេញចន្លោះនេះ របបបណ្តឹងជំទាស់ដិតចិត្តនេះត្រូវតែមានជាចាំបាច់ ។ មូលហេតុនៃបណ្តឹងជំទាស់ដិតចិត្តនេះ មានលក្ខណៈអរូបីពីព្រោះកំណត់តែកាលៈទេសៈដែលបណ្តាលឱ្យមានការលំអៀង ក្នុងជម្រះក្តី ។ ករណីជាក់ស្តែង គឺករណីដែលចៅក្រមជាមិត្តស្និទ្ធស្នាលនឹងភាគីណាម្នាក់ ឬ ជាសត្រូវ ឬ ករណីដែលចៅក្រមមានការទាក់ទងនឹងផលប្រយោជន៍ផ្នែកទ្រព្យសម្បត្តិក្នុងរឿងក្តីនោះ (ដូចជាករណីដែលចៅក្រមម្ចាស់ហ៊ុនចម្បងនៃក្រុមហ៊ុនរបស់ភាគីណាមួយជាដើម) ។ ប៉ុន្តែ ជាគោលការណ៍ការដឹកនាំនីតិវិធីវិញ ភាគីមិនអាចយកមកធ្វើជាមូលហេតុនៃបណ្តឹងជំទាស់ដិតចិត្តបានទេ ។ ម្យ៉ាងវិញទៀតចំពោះកំណត់គោលបំណងពេលវេលាដើម្បីប្តឹងជំទាស់ដិតចិត្ត ដែលត្រូវធ្វើមុនពេលចាប់ផ្តើមការវិនិច្ឆ័យនូវអង្គហេតុ ពីព្រោះបើភាគីមានសិទ្ធិប្តឹងជំទាស់ដិតចិត្តពេលណាក៏បានដែរនោះ នឹងធ្វើឲ្យមានភាពស្មុគស្មាញ លើកលែងតែចំពោះករណីដែលភាគីនោះ មិនបានដឹងអំពីមូលហេតុដែលអាចប្តឹងជំទាស់ដិតចិត្ត ឬ ករណីដែលមូលហេតុនៃបណ្តឹងជំទាស់ដិតចិត្តបានកើតឡើងនៅពេលក្រោយ ដោយសារគ្មានលទ្ធភាពប្តឹងមុន ។

### ២.២.២.៤ ការប្តឹងជំទាស់ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

បណ្តឹងជំទាស់ គឺជាប្រព័ន្ធនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលឯករាជ្យ និង សង្ខេប ដែលអាចធ្វើឡើងចំពោះដីកាសម្រេចដែលមិនមែនជាសាលក្រម ឬ សាលដីកា ។ ដីកាសម្រេចទាំងអស់មិនសុទ្ធតែអាចប្តឹងជំទាស់បានទេ គឺលុះត្រាតែមានច្បាប់ចែង អនុញ្ញាតឲ្យប្តឹងជំទាស់បាន ទើបអាចប្តឹងជំទាស់បាន ចំពោះដីកាសម្រេចលើបណ្តឹងជំទាស់ មិនអាចប្តឹងជំទាស់ទៀតបានឡើយ [98]។ ឧទាហរណ៍ មាត្រា ៥១ បណ្តឹងតវ៉ាចំពោះការដឹកនាំនីតិវិធីបណ្តឹង ក្នុងករណីដែលភាគីបានធ្វើបណ្តឹងតវ៉ា ចំពោះការដឹកនាំការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការចាត់ចែងរបស់តុលាការ តាមបញ្ញត្តិនៃកថាខណ្ឌទី១ នៃមាត្រា ៥០ (សិទ្ធិឱ្យបំភ្លឺ ជាអាទិ៍ ) តុលាការត្រូវសម្រេចសេចក្តី ចំពោះបណ្តឹងតវ៉ាដោយដីកាសម្រេច ។

---

[97] សូម មើលក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ២៨

[98] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ២៥៩ កថាខណ្ឌទី២

ត្រង់មាត្រា ៩១ ចំពោះដីកាសម្រេចអំពីការតវ៉ា ដែលកំណត់ក្នុងមាត្រានេះ មិនអាចបណ្ដឹងជំទាស់បានទេ[99]។ ប៉ុន្តែចំពោះការប្ដឹងជំទាស់នៅក្នុងដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺក្រមនីតិវិធីរដ្ឋប្បវេណី បានបញ្ញត្តិឱ្យភាគីប្ដឹងជំទាស់ចំពោះការសម្រេចសេចក្ដី ដូចជាដីកាសម្រេចបង្គាប់ឱ្យតតិយជនផ្តល់ឯកសារ មាត្រា ១៥២ កថាខណ្ឌទី៣ ក្នុងករណីដែលតុលាការចេញដីកាសម្រេចចំពោះតតិយជនក្រៅពីភាគី ។ ផល ប្រយោជន៍ក្នុងការប្ដឹងជំទាស់ត្រូវបានទទួលស្គាល់ចំពោះភាគី ឬ តតិយជនដែលបាត់បង់នូវផលប្រយោជន៍ ដោយសារដីកាសម្រេចដើម ។ អំឡុងពេលបណ្ដឹងជំទាស់ត្រូវធ្វើឡើងក្នុង ១ (មួយ) សប្ដាហ៍ដោយគិតចាប់ពី ថ្ងៃដែលទទួលដំណឹងអំពីដីកាសម្រេច។ បណ្ដឹងជំទាស់ ត្រូវដាក់ពាក្យបណ្ដឹងជំទាស់នៅតុលាការដើម [100]។ នៅ ក្នុងពាក្យបណ្ដឹងជំទាស់ គួរចុះអំពីមូលហេតុច្បាស់លាស់នៃការសុំលុបចោល ឬ ផ្លាស់ប្តូរនូវដីកាសម្រេចដើម ក៏ ប៉ុន្តែ ប្រសិនបើមិនសរសេរអំពីមូលហេតុនៃបណ្ដឹងជំទាស់នោះ ក៏បណ្ដឹងជំទាស់គ្មានសុពលភាពដែរ ។ ក្នុងករណី ដែរពាក្យបណ្ដឹងជំទាស់មិនមានសរសេរអំពីមូលហេតុទេ ដើមបណ្ដឹងជំទាស់គប្បីដាក់លិខិតបញ្ជាក់អំពីមូលហេតុ នៃជំទាស់នោះទៅតុលាការនៃបណ្ដឹងជំទាស់នោះ ក្នុងអំឡុងពេលចាប់ពីរ សប្ដាហ៍ គិតចាប់ពីថ្ងៃបានដាក់ពាក្យ បណ្ដឹងជំទាស់នោះ[101]បណ្ដឹងជំទាស់ត្រូវផ្អាកអនុភាពនៃដីកាសម្រេចដើម[102]។

[99] សូមមើល សេចក្ដីកំណត់មាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រង់មាត្រា ៩១
[100] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ៣០១ កថាខណ្ឌទី១
[101] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ៣០១ កថាខណ្ឌទី២
[102] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មាត្រា ៣០៥ កថាខណ្ឌទី១

# ជំពូកទី៣
# ការបញ្ចប់ និងអានុភាពនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ការបញ្ចប់ និង អានុភាពនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាកិច្ចមួយដែលតុលាការបានរៀបចំសេចក្តីអះអាងរបស់ភាគី កំណត់ចំណុចវិវាទនៃរឿងក្តី និងរៀបចំភស្តុតាងទាក់ទងចំណុចវិវាទនៃរឿងក្តី បានចប់សព្វគ្រប់ ។ ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នាំឱ្យមានអនុភាពដល់ភាគី មិនអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីទៀតទេ ។ លើកលែងតែមធ្យោបាយនោះ តុលាការអនុញ្ញាតដោយពិចារណាទៅលើរឿងក្តី ការយឺតយ៉ាវនីតិវិធីបណ្តឹង ឬ ដោយគ្មានកំហុសរបស់ភាគី ។

## ៣.១.ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### ៣.១.១.ការបញ្ចប់អំពីអង្គហេតុដែលត្រូវធ្វើការបញ្ជាក់

ពេលដែលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានរៀបចំសេចក្តីអះអាងរបស់ ភាគីលើធ្វើការបញ្ជាក់ តាមរយៈការពិនិត្យភស្តុតាង នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដែលនឹងធ្វើបន្ទាប់ពីនោះ[103]។ តុលាការ និងភាគីទាំងសងខាង ត្រូវមានការទទួលស្គាល់រួមគ្នាចំពោះភស្តុតាងដែលបានដាក់មកផងដែរដែលវាអាចធានាអំពីការពិនិត្យភស្តុតាងជាសមូហវិធី នៅពេលទាញហេតុផលដោយផ្ទាល់មាត់បាន[104]។ ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាចំណុចស្នូលមួយដែលតុលាការបានកំណត់ចំណុចវិវាទនៃរឿងក្តីរបស់ភាគី និងបានរៀបចំភស្តុតាងទាក់ទងនិងចំណុចវិវាទបានសព្វគ្រប់ ប៉ុន្តែតុលាការ ត្រូវបញ្ជាក់ជាមួយភាគី ថាអង្គហេតុថាខ្លះជាចំណុចវិវាទ ហើយតុលាការត្រូវបញ្ជាក់អង្គហេតុណាខ្លះដែលភាគីនឹងត្រូវបំភ្លឺនៅពេលពិនិត្យភស្តុតាងនៅពេលក្រោយ ។

### ៣.១.២.ការកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានបញ្ចប់សព្វគ្រប់ហើយនោះ តុលាការត្រូវកំណត់កាលបរិច្ឆេទ ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីមកចូលរួម[105]។ ភាពចាំបាច់នៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ពោលគឺតុលាការគោរពគោលការណ៍ជម្រះក្តីដោយផ្ទាល់មាត់ ម្យ៉ាងវិញទៀតដើម្បីចេញសាលក្រមលើបណ្តឹង តុលាការចាំបាច់ត្រូវតែឆ្លងកាត់នូវការទាញហេតុផលដោយផ្ទាល់មាត់ លើលែងចំពោះរឿងក្តី ឬ ចំណុចណាដែលត្រូវសម្រេចដោយដីកាសម្រេច ដែលតុលាការកំណត់ថា ត្រូវធ្វើនីតិវិធីទាញហេតុផលដោយផ្ទាលមាត់ ឬ មិនត្រូវធ្វើ ប៉ុន្តែករណីនេះតុលាការអាចសួរភាគីបាន [106]។

---

[103] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ១០៧

[104] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ១២៧

[105] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ១១៣

[106] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ១១៤ កថាខណ្ឌទី១ កថាខណ្ឌទី២ ។

## ៣.២.អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ក្រោយពីបានធ្វើការកំណត់ចំណុចវិវាទ និងបានកំណត់កាលបរិច្ឆេទនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយនោះ អានុភាពនៃការបញ្ចប់នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដូចជា៖

### ៣.២.១.ការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន

ក្រោយពីបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយនោះ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួនថ្មីបានទៀតទេ លើកលែងតែក្នុងករណីដែលមធ្យោបាយនោះទាក់ទងនឹងចំណុចវិវាទ ដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន ឬ ករណីដែលភាគីបានធ្វើសេចក្តីបញ្ជាក់ដំបូងថា ខ្លួនមិនអាចដាក់មធ្យោបាយនោះមុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយគ្មានកំហុសធ្ងន់ធ្ងរ និងករណីដាក់មធ្យោបាយថ្មីនោះ មិនធ្វើឱ្យមានការយឺតយ៉ាវដល់នីតិវិធីបណ្តឹង[107]។ ដោយផ្អែកទៅលើគោលការណ៍នៃការដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួន គឺភាគីត្រូវដាក់ឱ្យតុលាការនៅពេលណាមួយដែលសមរម្យទៅតាមដំណើរការនៃបណ្តឹង[108]។ ដូច្នេះ ប្រសិនបើមានការអនុញ្ញាត ឱ្យភាគីអាចដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួននៅក្រោយបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញ ហេតុផលបាននោះ ការដែលត្រូវកំណត់ចំណុចវិវាទរួចរាល់តាមរយៈការរៀបចំនូវការអះអាងរបស់ភាគី និង ការបង្រួម ភស្តុតាងដែលត្រូវពិនិត្យ នឹងពុំមានន័យខ្លឹមសារអ្វីឡើយ[109]។ ប៉ុន្តែ យ៉ាងណាក៏ដោយ ភាគីអាចដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួននៅក្រោយ បញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ក្នុងករណីដែលមធ្យោបាយនោះ គឺពាក់ព័ន្ធនឹងចំណុចដែលតុលាការត្រូវធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ។

### ៣.២.២ ការជំនុំជម្រះបណ្តឹងឧទ្ធរណ៍

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលបានធ្វើនៅក្នុងជំនុំជម្រះលើកទី១ មានអនុភាពក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍[110]។ ពោលគឺភាគីពុំអាចបន្ថែមសេចក្តីអះអាងថ្មីទៀតដោយសេរី នៅក្នុងជំនុំជម្រះបណ្តឹងឧទ្ធរណ៍នោះ វានឹងបណ្តាលឱ្យការវិនិច្ឆ័យដែលបានធ្វើនៅសាលាដំបូងនោះពុំមានន័យទៅវិញ ។ ម្ល៉ោះហើយ កថាខណ្ឌទី២ នៃមាត្រា ២៧៤ ក្រមនីតិវិធីរដ្ឋប្បវេណីនេះ អនុភាពនៃការបាត់បង់សិទ្ធិដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន ក្នុងការជំនុំជម្រះទី១ មាត្រា ១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ក៏ត្រូវរក្សាក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ដែរ [111]។

[107] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ១០៨

[108] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៩៣

[109] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី១៖ នីតិវិធីបណ្តឹង បោះពុម្ពឆ្នាំ២០០៨ ទំព័រទី ៨៦

[110] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ២៧៤ កថាខណ្ឌទី២

[111] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃនីតិវិធីរដ្ឋប្បវេណី មាត្រា ២៧៤ កថាខណ្ឌទី២

# សេចក្តីសន្និដ្ឋាន

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីមួយដែលមានភាពចាំបាច់នៅក្នុងការចាប់ផ្តើមដំបូងនៅក្នុងការដោះស្រាយវិវាទពាក់ព័ន្ធនឹងរឿងក្តីរដ្ឋប្បវេណីនៃនីតិវិធីជំនុំជម្រះលើកទី១ បន្ទាប់ពីនីតិវិធីបណ្តឹងដាក់រួចមក ដែលធ្វើឡើងដើម្បីត្រៀមរៀបចំនូវការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីចេញសាលក្រមលើបណ្តឹងដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន ។ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលពោលគឺទាមទារឱ្យតុលាការគោរពគោលការណ៍នានា រួមទាំងការដឹកនាំ និង ចាត់ចែង ព្រមទាំងការផ្សះផ្សាតាមកំណត់ហេតុសះជាបញ្ចប់វិវាទ ដោយមិនឆ្លងកាត់ការជម្រះក្តី ដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី និងទាមទារឱ្យភាគីមានការយល់ច្បាស់នៃគោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល សកម្មភាពដែលភាគីមានសិទ្ធិនៅក្នុងនីតិវិធីត្រៀម និង អនុភាពនៃការបញ្ចប់នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

ទន្ទឹមនឹងនេះ ឃើញថានីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីមួយដែលតុលាការដឹកនាំការទាញហេតុផលដោយផ្ទាល់មាត់(គោលការណ៍ផ្ទាល់មាត់) និងការរៀបចំចាត់ចែងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីសម្រេចគោលបំណងនៃការរៀបចំការអះអាងរបស់ភាគី ដែលនាំឱ្យតុលាការដឹងថា អង្គហេតុណាខ្លះ ជាអង្គហេតុដែលមានវិវាទ ឬ គ្មានវិវាទ ។ ការបំភ្លឺចំណុចវិវាទ ដែលភាគីយល់មិនស្របគ្នាត្រូវផ្អែកលើភស្តុតាង និងរៀបចំនូវភស្តុតាងដែលទាក់ទងនិងចំណុចវិវាទ ដើម្បីធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អន់ល្អត់ ។

សរុបមក នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជានីតិវិធីដែលចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីចេញសាលក្រមទៅលើបណ្តឹង ។ ដូចនេះ ប្រសិនបើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលប្រព្រឹត្តទៅយ៉ាងរលូនដោយកំណត់ ចំណុចវិវាទបានយ៉ាងត្រឹមត្រូវ និងធ្វើការរៀបចំភស្តុតាងបានល្អនោះនាំឱ្យកិច្ចដំណើការនីតិវិធីនៅក្នុងការទាញហេតុផលផ្ទាល់មាត់មានភាពងាយស្រួល និងឆាប់រហ័សក្នុងការផ្តល់យុត្តិធម៌ដល់គូភាគី ។

# អនុសាសន៍

យោងតាមការសិក្សាស្រាវជ្រាវលើប្រធានបទសារណាខាងលើ នីតិវិធីត្រៀមសម្រាប់សម្រាប់ការទាញហេតុផល គឺធ្វើឡើងដើម្បីសម្រេចឱ្យបាននូវគោលបំណងនៃការរៀបចំការអះអាងរបស់ភាគី កំណត់ចំណុចវិវាទ និងរៀបចំភស្តុតាងទាក់ទងនិងចំណុចវិវាទនៃរឿងក្តី តាមបញ្ញត្តិនៃមាត្រា១០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ប៉ុន្តែក្នុងនោះយើងឃើញថា សកម្មភាពមួយចំនួនរបស់តុលាការ និងភាគី ក៏មានចែងជាក់លាក់ក្នុងការកំណត់នៃសិទ្ធិ និងការផ្សះផ្សាចំពោះចំណុចវិវាទ ចំពោះការដឹកនាំចាត់ចែង នៃដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីបង្រួមនូវចំណុចវិវាទរបស់គូភាគី ដែលទាមទារឱ្យតុលាការ ធ្វើការដឹកនាំនីតិវិធី ព្រមទាំងអនុវត្តសិទ្ធិឱ្យបំភ្លឺចំពោះអង្គហេតុ និងអង្គច្បាប់ ដែលទាក់ទងនិងបណ្តឹងដើម្បីឱ្យមានការភាពច្បាស់លាស់ ។

ចំណែកឯភាគី អាចអនុវត្តសិទ្ធិចំពោះបណ្តឹងតវ៉ាចំពោះការដឹកនាំ និងចាត់ចែងរបស់តុលាការ ដោយមូលហេតុមិនត្រឹមត្រូវ និងមានករណីកិច្ចស្រាវជ្រាវឱ្យបានលំអិតជាមុន នូវទំនាក់ទំនងនៃអង្គហេតុ សាក្សី ភស្តុតាងផ្សេងៗ ឱ្យបានគ្រប់គ្រាន់ច្បាស់សាល់ ដើម្បីជាមធ្យោបាយតទល់ និងការពារខ្លួន មុនពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ។ ប៉ុន្តែចំពោះបញ្ហាចោទនៃប្រធានបទខាងលើ គឺទាមទារឱ្យភាគីស្គាល់អំពីសិទ្ធិរបស់ខ្លួន រួមការចាត់ចែងនៃការដឹកនាំរបស់តុលាការ ព្រោះក្នុងនីតិវិធីបណ្តឹងរដ្ឋប្បវេណី តុលាការគឺជាតុលាការអកម្ម បានន័យថា តុលាការមិនអាចយកអង្គហេតុណា ដែលភាគីណាមួយមិនបានអះអាង មកធ្វើជាមូលដ្ឋាននៃសាលក្រមឡើយ ន័យនេះមិនមែនគ្រប់ការអះអាងរបស់ភាគី ត្រូវយកមកធ្វើជាមូលដ្ឋានសាលក្រមឡើយ ពោលគឺតុលាការ យកតែអង្គហេតុណាដែលពិនិត្យឃើញថា អង្គហេតុនោះមានវិវាទ ឬ គ្មានវិវាទ ព្រោះតុលាការទទួលស្គាល់អង្គហេតុដោយផ្អែកលើភស្តុតាង ឬ អង្គហេតុណាដែលគូភាគីបានអះអាង ដែលតុលាការអាចទទួលស្គាល់ដោយមិនចាំបាច់ផ្អែកលើភស្តុតាង ។

ដូច្នេះដើម្បីជំនុំជម្រះក្តីយុត្តិធម៌ជូនភាគី ដែលត្រូវគេបំពាន ឬ ក្លាយកម្មវត្ថុវិវាទ ការការពារដោយតុលាការ គប្បីតុលាការធានាឱ្យបាននូវគោលបំណងដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន តុលាការត្រូវប្រឹងប្រែង ដើម្បីរ៉ាប់រងបណ្តឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌ និងឆាប់រហ័ស ផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណី ឬ បញ្ញត្តិនៃច្បាប់ពិសេស ឯភាគីមានសិទ្ធិទាមទារ និងប្តឹងឧប្រា-ស្រ័យ ដែលច្បាប់ទទួលស្គាល់ ព្រមទាំងអនុវត្តបណ្តឹងរដ្ឋប្បវេណី ដោយសុចរិតភាព និង ភាពស្មោះត្រង់ ។

# ឯកសារយោង

## ឯកសារយោង

១-ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ។

២-ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។

៣-សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៤-សៀវភៅសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី នីតិវិធីបណ្តឹង ៖ ភាគ១ ។

# ឧបសម្ព័ន្ធ

# ឧសម្ព័ន្ធទី១

ពាក្យបណ្តឹងលេខ ៧១០ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩
របស់សាលាដំបូងខេត្តកណ្តាល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តកណ្ដាល
សំណុំរឿងរដ្ឋប្បវេណី
លេខៈ 710
ថ្ងៃទី 9 ខែ 8 ឆ្នាំ២០19

# ពាក្យបណ្ដឹង

**ដើមចោទ** :-ឈ្មោះ ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ០៥១ ផ្លូវលេខ២១ ភូមិសំប៉ាន ឃុំកោះធំ(ខ) ស្រុកកោះធំ។

**សហចុងចម្លើយ**:

-ឈ្មោ ភេទស្រី កើតឆ្នាំ១៩៨៥ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិព្រែកឫស្សី ឃុំកំពង៖ កោះធំ ខេត្តកណ្ដាល។

-ឈ្មោះ ; ភេទប្រុស កើតឆ្នាំ១៩៨២ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិព្រែកឫស្សី ឃុំ កោះធំ ខេត្តកណ្ដាល។

**<u>សូមគោរពជូន</u>**

**លោកប្រធានសាលាដំបូងខេត្ត**

*<u>សូមទានជ្រាប</u>*

**<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ:</u>**

១-ប្ដឹងសុំទាមទារឲ្យសហចុងចម្លើយសងប្រាក់ដើមចំនួន ៥៣,៦៥៩,០០០៛ (ហាសិបបីលាន ប្រាំមួយសែនប្រាំម៉ឺនប្រាំបួនពាន់) រៀល។

២-សុំទាមទារឲ្យសហចុងចម្លើយបង់ការប្រាក់ ១.៥% ក្នុងមួយខែ។

៣-សុំទាមទារជម្ងឺចិត្តខាតបង់ពេលវេលាសរុបចំនួន ៣០,០០០,០០០៛ (សាមសិបលាន) រៀល។

៤-សុំអនុវត្តសាលក្រមជាបណ្ដោះអាសន្ន។

៥-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

**<u>អង្គហេតុចាំបាច់នូវការទាមទារ:</u>**

កាលពីថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០១៦ សហចុងចម្លើយឈ្មោះ ហេង ស្រ៊ន និងប្ដីឈ្មោះ ស្រ៊ុ វុទ្ធី បានខ្ចីប្រាក់ពីខ្ញុំបាទចំនួន ៥៦,០០០,០០០៛ (ហាសិបប្រាំមួយលានរៀលគត់) ដោយគិតអត្រាការ ប្រាក់ ១,៥% ហើយខ្ចីប្រាក់នេះមានរយៈពេល ១២០ ខែ។ ហើយត្រូវសន្យាសងត្រឡប់មកអោយ ខ្ញុំបាទវិញទាំងដើមទាំងការជាដាច់ខាត ដោយក្នុងការខ្ចីប្រាក់នេះភាគីចុងចម្លើយមានកាតព្វកិច្ចបង់ ប្រាក់មកឲ្យខ្ញុំបាទវិញតាមតារាងសងប្រាក់។ ហើយសហចុងចម្លើយយល់ព្រមដាក់ទ្រព្យសម្បត្តិ ដើម្បីបញ្ចាំដោយគ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ។

**<u>មូលហេតុនៃការទាមទារ:</u>**

ចាប់ពីថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១៧ ហូតមកដល់បច្ចុប្បន្នសហចុងចម្លើយឈ្មោះ ហេង ស្រ៊ន និងប្ដីឈ្មោះ ស្រ៊ុ វុទ្ធី ពុំបានអនុវត្តកាតព្វកិច្ចដូចដែលមានក្នុងកិច្ចសន្យាទេ។ ប៉ុន្តែសហចុងចម្លើយនៅ តែមិនព្រមធ្វើការដោះស្រាយសងបំណុលមកឲ្យខ្ញុំបាទទៀត ជាហេតុធ្វើឲ្យខ្ញុំបាទបាត់បង់ផល ប្រយោជន៍យ៉ាងធ្ងន់ធ្ងរ។ សកម្មភាពទាំងនេះអាចបញ្ជាក់បានថា ចុងចម្លើយពុំមានឆន្ទៈក្នុងការ អនុវត្តកាតព្វកិច្ចសងប្រាក់មកឲ្យខ្ញុំបាទនោះទេ ជាហេតុធ្វើឲ្យកិច្ចសន្យាខ្ចីចង់ការប្រាក់ ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០១៦ រវាងខ្ញុំបាទ និងសហចុងចម្លើយឈ្មោះ ហេង ស្រ៊ន និងប្ដីឈ្មោះ ស្រ៊ុ វិទ្ធី មិនអាចអនុវត្តបាន។

មួយវិញទៀតដើម្បីការពារផលប្រយោជន៍របស់ខ្ញុំបាទ ការប្រកាសអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើមពិតជាមានសារៈសំខាន់ណាស់ដល់ការធានាចំពោះការអនុវត្តសិទ្ធិលើបំណុលខាងលើនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាជួយចេញសាលក្រមតាមការទាមទារខាងលើឲ្យខ្ញុំបាទដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

កណ្តាល ថ្ងៃទី ..០១... ខែ[illegible] ឆ្នាំ២០១៩

ស្នាមមេដៃស្តាំ

# ឧបសម្ព័ន្ធទី២

ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់

ប្រដាប់ក្តីតុលាការក្រៅពីពន្ធលេខៈ ២៨២

ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០

របស់សាលាដំបូងខេត្តកណ្តាល

នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ៨០៣

ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

លេខ: ...... ដកសរ/២០

# ដីកាសម្រេចបង្គាប់ឲ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

យើង ចៅក្រមសាលាដំបូងខេត្តកណ្ដាល ។

_បានឃើញមាត្រា ៦២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

_បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី ខែ ឆ្នាំ ២០២០ របស់សាលាដំបូងខេត្តកណ្ដាល ។

ដើមចោទឈ្មោះ: ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ទី០២ ខែ មីនា ឆ្នាំ១៩៥៨ និង ប្រពន្ធឈ្មោះ: ថ្ងៃខែឆ្នាំកំណើតទី០១ ខែមីនា ឆ្នាំ១៩៥៨ មានទីលំនៅបច្ចុប្បន្ននៅភូមិតាក្ដុលត្បូង សង្កាត់តាក្ដុល ក្រុងតាខ្មៅ ខេត្តកណ្ដាល ។

ដែលមានកម្មវត្ថុបណ្ដឹង៖

## យល់ឃើញថា

ដើម្បីតុលាការដំណើរការនីតិវិធីបណ្ដឹង និងសកម្មភាពផ្សេងៗទៀត ទៅតាមច្បាប់ទាក់ទិននឹងសំណុំរឿងក្ដីខាងលើ គប្បីតម្រូវឲ្យដើមចោទឈ្មោះ: និង ប្រពន្ធឈ្មោះ: បង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពន្ធចំនួន ១០០.០០០ (មួយសែន)រៀល តាមមាត្រា ៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ។

## ហេតុដូច្នេះសម្រេច

_បង្គាប់ឲ្យដើមចោទឈ្មោះ: ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ទី០២ ខែ មីនា ឆ្នាំ១៩៥៨ និង ប្រពន្ធឈ្មោះ: ថ្ងៃខែឆ្នាំកំណើតទី០១ ខែមីនា ឆ្នាំ១៩៥៨ មានទីលំនៅបច្ចុប្បន្ននៅភូមិតាក្ដុលត្បូង សង្កាត់តាក្ដុល ក្រុងតាខ្មៅ ខេត្តកណ្ដាល បង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពន្ធចំនួន ១០០.០០០ (មួយសែន) រៀល នៅសាលាដំបូងខេត្តកណ្ដាល ក្នុងរយៈពេលមួយសប្ដាហ៍បន្ទាប់ពីថ្ងៃទទួលបានដីកានេះ ជាកំណត់ដើម្បីតុលាការចាត់ការរឿងក្ដីនេះតាមច្បាប់ ។

ថ្ងៃ ៣ ៤ ៣ កើត/រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
កណ្ដាល,ថ្ងៃទី១ ខែ វិច្ឆិកា ឆ្នាំ២០២០

**ចៅក្រម**

ការបង់ត្រូវធ្វើឡើង

# ឧបសម្ព័ន្ធទី៣

ដីកាកោះដើមចោទ ឲ្យចូលរួមស្ដីពី
នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល
ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០២០
របស់សាលាដំបូងខេត្តកណ្ដាល
នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ៨២២
ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

# ដីកាកោះ

យើង ចៅក្រមសាលាដំបូងខេត្តកណ្ដាល

អញ្ជើញ ៖ ឈ្មោះ ភេទប្រុស អាយុ ៣៥ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះលេខ១៦ ផ្លូវ២ ភូមិតាខ្មៅ១ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល

| | |
|---|---|
| សញ្ញាណរឿងក្ដី និង ភាគី | សំណុំរឿងរដ្ឋប្បវេណីលេខ: ៨២២ ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ២០២០។<br>ការទាមទារដោយដើមចោទ ៖ ប្ដឹងសុំរំលាយកិច្ចសន្យាទិញ_លក់ដីនិងផ្ទះ ។<br>+ ដើមចោទឈ្មោះ ភេទប្រុស អាយុ ៦៦ ឆ្នាំ និងប្រពន្ធឈ្មោះ ។<br>+ចុងចម្លើយឈ្មោះ ភេទប្រុស អាយុ ៣៥ឆ្នាំ ។ |
| កាលបរិច្ឆេទ និង ទីកន្លែងដែលបង្ហាញខ្លួន | ថ្ងៃទី២៧ ខែ វិច្ឆិកា ឆ្នាំ ២០២០ វេលាម៉ោង៩.០០នាទីព្រឹក ។<br>☑សាលាដំបូងខេត្តកណ្ដាល ☐ បន្ទប់សវនាការទី....... ☑បន្ទប់ (ណ) |
| ប្រភេទនៃកាលបរិច្ឆេទ<br>( សំគាល់ដោយសញ្ញា ☑ ) | ☑នីតិវិធីត្រៀម ☐ទាញហេតុផលផ្ទាល់មាត់ ☐ប្រកាសសាលក្រម<br>............................................................................................................. |
| ប្រភេទនៃឯកសារភ្ជាប់មកជាមួយ<br>( សំគាល់ដោយសញ្ញា ☑ ) | ☐ ឯកសារទាក់ទងនឹងបណ្ដឹង |

សូមបង្ហាញខ្លួនដូច ដែលបានចែងខាងលើនេះ ។

ថ្ងៃពុធ ៣កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
កណ្ដាល, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០២០
**ចៅក្រម**

យើង..............................ជា....................បានប្រគល់ ដីកាកោះនេះ
ឱ្យឈ្មោះ....................មានទីលំនៅបច្ចុប្បន្ននៅភូមិ................ឃុំ...............
ស្រុក............................ខេត្ត.....................នៅថ្ងៃទី.......ខែ...........ឆ្នាំ២០២០
ហើយយើងបានប្រាប់ថាសាមីខ្លួន ត្រូវប្រគល់ចុងដីកាកោះនេះ ដល់ក្រឡាបញ្ជី
នៅពេលដែលខ្លួនចូលទៅចំពោះមុខតុលាការខេត្តកណ្ដាល ។
**ក្រឡាបញ្ជី បន្ទប់ណា)**

អ្នកប្រគល់

អ្នកទទួល

# ឧបសម្ព័ន្ធទី៤

ដីកាកោះចុងចម្លើយ ឲ្យចូលរួមស្តីពី
នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល
ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០២០
របស់សាលាដំបូងខេត្តកណ្តាល
នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ៨២២
ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

# ដីកាកោះ

យើង ចៅក្រមសាលាដំបូងខេត្តកណ្ដាល

អញ្ជើញ ៖ ឈ្មោះ ភេទប្រុស អាយុ ៣៥ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះលេខ១៦ ផ្លូវ២ ភូមិតាខ្មៅ១ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ( ជាចុងចម្លើយ ) ។

| | |
|---|---|
| សញ្ញាណរឿងក្ដី និង ភាគី | សំណុំរឿងរដ្ឋប្បវេណីលេខ: ៨២២ ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ២០២០។<br>ការទាមទារដោយដើមចោទ ៖ ប្ដឹងសុំរំលាយកិច្ចសន្យាទិញ_លក់ដីនិងផ្ទះ ។<br>+ ដើមចោទឈ្មោះ ភេទប្រុស អាយុ ៦៦ ឆ្នាំ និងប្រពន្ធឈ្មោះ<br>។<br>+ចុងចម្លើយឈ្មោះ ភេទប្រុស អាយុ ៣៥ឆ្នាំ ។ |
| កាលបរិច្ឆេទ និង ទីកន្លែងដែលបង្ហាញខ្លួន | ថ្ងៃទី២៧ ខែ វិច្ឆិកា ឆ្នាំ ២០២០ វេលាម៉ោង៩.០០នាទីព្រឹក ។<br>☑សាលាដំបូងខេត្តកណ្ដាល ☐ បន្ទប់សវនាការទី....... ☑បន្ទប់ (ណ) |
| ប្រភេទនៃកាលបរិច្ឆេទ<br>( សំគាល់ដោយសញ្ញា ☑ ) | ☑នីតិវិធីត្រៀម ☐ ទាញហេតុផលផ្ទាល់មាត់ ☐ប្រកាសសាលក្រម<br>........................................................................................................ |
| ប្រភេទនៃឯកសារភ្ជាប់មកជាមួយ<br>( សំគាល់ដោយសញ្ញា ☑ ) | ☐ ឯកសារទាក់ទងនឹងបណ្ដឹង |

សូមបង្ហាញខ្លួនដូច ដែលបានចែងខាងលើនេះ ។

ថ្ងៃពុធ ៣កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
កណ្ដាល, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០២០
**ចៅក្រម**

យើង..............................ជា....................បានប្រគល់ ដីកាកោះនេះ
ឱ្យឈ្មោះ......................មានទីលំនៅបច្ចុប្បន្ននៅភូមិ.................ឃុំ...............
ស្រុក..............................ខេត្ត.......................នៅថ្ងៃទី.......ខែ...........ឆ្នាំ២០២០
ហើយយើងបានប្រាប់ថាសាម៉ីខ្លួន ត្រូវប្រគល់ចុងដីកាកោះនេះ ដល់ក្រឡាបញ្ជី
នៅពេលដែលខ្លួនចូលទៅចំពោះមុខតុលាការខេត្តកណ្ដាល ។
**ក្រឡាបញ្ជី បន្ទប់ណ)**

អ្នកប្រគល់

អ្នកទទួល

# ឧបសម្ព័ន្ធទី៥

លិខិតអញ្ជើញមេធាវី ឲ្យចូលរួមស្តីពី
នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល
ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០២១
របស់សាលាដំបូងខេត្តកណ្តាល
នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ៨២២
ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០

ភភ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

លេខ៖...១៣.../២១

# លិខិតអញ្ជើញ

យើង ក្រុមសាលាដំបូងខេត្តកណ្តាល

អញ្ជើញ ៖ ឈ្មោះ ភេទប្រុស អត្តលេខ ៥៦០និងលោកមេធាវី ប្រុស អត្តលេខ ២១៨៦T ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា មានទីតាំងការិយាល័យមេធាវី ការិយាល័យមេធាវី៖ អាសយដ្ឋានអគារលេខា AA១៨ ផ្លូវ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ (តំណាងដោយអាណត្តិចុងចម្លើយ ) ។

| | |
|---|---|
| សញ្ញាណរឿងក្តី និង ភាគី | សំណុំរឿងរដ្ឋប្បវេណីលេខៈ ៨២២ ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ២០២០។<br>ការទាមទារដោយដើមចោទ ៖ ប្តឹងសុំលោយកិច្ចសន្យាទិញ លក់ដីនិងផ្ទះ ។<br>+ ដើមចោទឈ្មោះ ទប្រុស អាយុ ៦៦ ឆ្នាំ និងប្រពន្ធឈ្មោះ<br>។<br>+ចុងចម្លើយឈ្មោះ ភេទប្រុស អាយុ ៣៥ឆ្នាំ ។ |
| កាលបរិច្ឆេទ និង ទីកន្លែងដែល បង្ហាញខ្លួន | ថ្ងៃទី ខែ . ឆ្នាំ ២០២១ វេលាម៉ោង៩.០០នាទីព្រឹក ។<br>☑ សាលាដំបូងខេត្តកណ្តាល ☐ បន្ទប់សវនាការទី.......☐ (ណ) |
| ប្រភេទនៃកាលបរិច្ឆេទ ( សំគាល់ដោយសញ្ញា ☑ | ☑ នីតិវិធីត្រៀម ☐ ទាញហេតុផលផ្ទាល់មាត់ ☐ ប្រកាសសាលក្រម<br>........................................................................................ |
| ប្រភេទនៃឯកសារភ្ជាប់មកជាមួយ | ☐ឯកសារទាក់ទងនឹងបណ្តឹង |

សូមបង្ហាញខ្លួនដូច ដែលបានចែងខាងលើនេះ ។

ថ្ងៃចន្ទ ១២កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
កណ្តាល ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០២១
ចៅក្រម

ក្រឡាបញ្ជី ៦ក តាក (បន្ទប់ណា)

ថ្ងៃទី 27 ខែមករា ឆ្នាំ ២០២១

អ្នកទទួល

# ឧបសម្ព័ន្ធទី៦

ទម្រង់របាយការណ៍បញ្ជូនស្តីពីប្រកាសការបញ្ជូន
ចុះថ្ងៃទី.... ខែមករា ឆ្នាំ២០២១
របស់សាលាដំបូងខេត្តកណ្តាល
នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ១៦៣
ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០២០

សាលាដំបូងខេត្តកណ្ដាល

# របាយការណ៍ពីការបញ្ជូន

ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី

| |
|---|
| កាលបរិច្ឆេទផ្ញើចេញ: ថ្ងៃទី ..... ខែ មករា ឆ្នាំ ២០២១<br>សំណុំរឿងរដ្ឋប្បវេណី លេខ: ១៦៣ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២០<br>ឈ្មោះឯកសារដែលត្រូវបញ្ជូន: សេចក្ដីប្រកាសស្ដីពី ការបញ្ជូន<br><br>ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: លោកស្រី សិត សុនី<br>អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: សាលាដំបូងខេត្តកណ្ដាល<br>ឈ្មោះជនដែលត្រូវទទួលការបញ្ជូន: លោក មេឃុំយាង ស្រុក ពួក ខេត្ត សៀមរាប (ដើម្បីបិទផ្សាយ) |

ហត្ថលេខា ឬស្នាមមេដៃអ្នកទទួលឯកសារដាក់ស្លែង: ........................................................................................

ប្រអប់ខាងក្រោមនេះត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន (កត្តាប្រៃសណីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី)

| | | |
|---|---|---|
| ទីកន្លែងដែលបានធ្វើការបញ្ជូន: .................................................................................................................. | | |
| ការបរិច្ឆេទនៃការបញ្ជូន: ថ្ងៃទី.................... ខែ...................... ឆ្នាំ..................... វេលាម៉ោង ..................... ព្រឹក-រសៀល | | |
| **វិធីដាក់ស្លែងក្នុងការបញ្ជូន** | | |
| ☐ ១ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ | |
| | ☐ ខ្ញុំបាទពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូន នូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអានអក្សរ ។ | |
| ☐ ២ | បានប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកដែល ត្រូវទទួលការបញ្ជូនដោយផ្ទាល់នៅទីកន្លែងដែលត្រូវបញ្ជូននោះទេ ។ | |
| | ☐ អ្នកបម្រើ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ: ☐ អ្នកនៅជាមួយ | |
| | ឈ្មោះ: ..................................................................................................................... | |
| ☐ ៣ | ឯកសារត្រូវបានទុកនៅឯទីកន្លែងត្រូវធ្វើការបញ្ជូន ដោយហេតុថាបុគ្គលខាងក្រោមនេះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល ។ | |
| | ☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបម្រើ<br>☐ អ្នកនៅជាមួយ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ: | |
| | ឈ្មោះ: ..................................................................................................................... | |
| ☐ ខ្ញុំបាទបានបញ្ជូនឯកសារតាមនីតិវិធីដូចខាងលើ | | |
| ☐ ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះ ។ | | |
| កាលបរិច្ឆេទធ្វើរបាយការណ៍: ថ្ងៃទី.......................... ខែ.......................... ឆ្នាំ................................ | | |
| ឈ្មោះ និងហត្ថលេខារបស់អ្នកធ្វើរបាយការណ៍:........................................ សិត សុនី ........................................ | | |

# ឧបសម្ព័ន្ធទី៧

ពាក្យសុំបញ្ចូលភស្តុតាងលេខ ០៥២

ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ២០២១

របស់សាលាដំបូងខេត្តកណ្តាល

នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ៦៥០

ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ០៥៤២
ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១

សាលាដំបូងខេត្តកណ្ដាល
ចូល លេខ 364
ថ្ងៃទី 12 ខែ 03 ឆ្នាំ2021
ម៉ោង 4 និង 04 នាទី

## <u>ពាក្យសុំបញ្ជូនពិនិត្យភស្តុតាង</u>

ខ្ញុំមេធាវី ជាមេធាវីតំណាងឲ្យអាណត្តិទាយកឈ្មោះ ភេទប្រុស (៣)
អាយុ ៤០ ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០២០០៣៥០៦១(០១) មានទីលំនៅបច្ចុប្បន្ន ភូមិស្វាយលិច ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដែលត្រូវជាដើមចោទ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ៦៥០ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្ដាល ។

ជូន
លោកចៅក្រម និងក្រឡាបញ្ជី
ទទួលបន្ទុក ពិនិត្យជាសមត្ថកិច្ច ។

**<u>សូមគោរពជូន</u>**

**លោក ចៅក្រមនៃសាលាដំបូងខេត្តកណ្ដាល**

*<u>សូមមេត្តាជ្រាប!</u>*

**<u>កម្មវត្ថុ៖</u>** សុំជូនពិនិត្យភស្តុតាង នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ៦៥០ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្ដាល ។

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **លោកចៅក្រម** មេត្តាជ្រាបថា កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២០ តុលាការសាលាដំបូងខេត្តកណ្ដាល បានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយនាងខ្ញុំជាមេធាវីតំណាងដោយអាណត្តិ បានចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅថ្ងៃទី ០១ ខែមីនា ឆ្នាំ២០២០ នេះផងដែរ ។ ដូច្នេះដើម្បីជាប្រយោជន៍របស់កូនក្តីខ្ញុំ ខ្ញុំស្នើសុំដាក់ភស្តុតាងដូចមានរៀបរាប់ខាងក្រោម៖

1. **កិច្ចសន្យាកក់ប្រាក់ទិញដី ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ២០២០ រវាងឈ្មោះ**

   ឈ្មោះ បានព្រមព្រៀងគ្នាទិញលក់ដី ០១ កន្លែង ទំហំសរុប ៣២៣៣ (បីពាន់ពីររយសាមសិបបី)ម៉ែត្រការ៉េ ក្នុងតម្លៃ១៧$ (ដប់ប្រាំពីរដុល្លារអាមេរិច) ក្នុង ១ម៉ែត្រការ៉េ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨០១២៧០៥-០០៩៧ ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៩ មានទីតាំងស្ថិតនៅភូមិតាឡើក ឃុំត្រពាំងវែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។ នៅត្រង់ត្រេទី២ បានកំណត់ថា *កិច្ចសន្យានេះធ្វើឡើងដោយមិនអាចកែប្រែតម្លៃលក់ទិញ ក្នុងកំឡុងពេលកិច្ចសន្យាមានសុពលភាពនៅឡើយ ក្នុងករណីអ្នកលក់កែប្រែតម្លៃលក់ ឬមិនលក់ដីវិញនោះ ប្រាក់ដែលបានកក់ជូនភាគីអ្នកលក់ត្រូវសងភាគីអ្នកទិញមួយគុណនឹង ៣ នៅលើទំហំផ្ទៃដីដែលបានលក់* ។ នៅត្រង់ត្រេទី៣ បានកំណត់ថា *ក្នុង*

Scanned with CamScanner

អាសយដ្ឋាន: ផ្ទះលេខ ១៨ ផ្លូវលេខ ២១ សង្កាត់ ផ្សារដើមគរ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: ០១២ ៧៥ ៧៤ ៩៣. Email: sannchuoy@gmail.com

ឈប់លក់ដីវិញ ដោយយកជាច់នូវប្រាក់កក់បានដែរ ដោយសារកិច្ចសន្យានេះមិនមានវិការៈក្នុងការបង្ហាញឆន្ទៈ ឬកូនក្តីខ្ញុំមិនបានបំពានកាតព្វកិច្ចធ្ងន់ធ្ងរឡើយ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកចៅក្រម** មេត្តាទទួលនូវពាក្យសុំបញ្ជូនពិនិត្យភស្តុតាងរបស់ខ្ញុំ ដើម្បីជាមូលដ្ឋានក្នុងការសម្រេចសេចក្តី ដោយក្តីអនុគ្រោះ។

សូម **លោកចៅក្រម** ទទួលនូវការគោរពអំពីខ្ញុំ ។

ថ្ងៃសុក្រ ១៤រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមីនា ឆ្នាំ២០២១

**ហត្ថលេខា និងត្រា**

Scanned with CamScanner

# ឧបសម្ព័ន្ធទី៨

កំណត់ហេតុស្ដីពី

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០

របស់សាលាដំបូងខេត្តកណ្ដាល

នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ១០០៤

ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

## កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

រឿងក្តី ៖ ប្តឹងសុំរំលាយកិច្ចសន្យាទិញ-លក់ដីនិងផ្ទះ ។
សំណុំរឿងលេខ៖ ១០០៤ ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៧ ។
ទីកន្លែង ៖ សាលាដំបូងខេត្តកណ្តាល ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២០
វេលាម៉ោង ប្រាំបួន សាមសិបនាទី ៩,០០ព្រឹក បានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដូចតទៅ:

ចៅក្រម៖ លោក ចៅក្រមសាលាដំបូងខេត្តកណ្តាល
ក្រឡាបញ្ជី ៖ លោកស្រី ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

ភាគីដែលបង្ហាញខ្លួនជាអាទិ៍ ៖

-ដើមចោទឈ្មោះ ភេទប្រុស អាយុ៦៦ឆ្នាំ និងប្រពន្ធឈ្មោះ អាយុ ៦៦ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិតាក្តុលត្បូង សង្កាត់តាក្តុល ក្រុងតាខ្មៅ ខេត្តកណ្តាល ។

មានតំណាងដោយអាណត្តិ៖ គ្មាន

-ចុងចម្លើយឈ្មោះ តេង សុត្ថា ភេទប្រុស អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិផ្ទះលេខ១៦ ផ្លូវ២ ភូមិតាខ្មៅ១ សង្កាត់ តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ។

-មានតំណាងដោយអាណត្តិ៖ លោក ជាមេធាវី អត្តលេខ: ១៥៨៣

-មានតំណាងដោយអាណត្តិ៖ លោក ជាមេធាវី អត្តលេ: ៥៦០

-មានតំណាងដោយអាណត្តិ៖លោក ជាមេធាវី អត្តលេខ: ២១៨៦T(កម្មសិក្សា)

-ដើមចោទឈ្មោ បានធ្វើសេចក្តីថ្លែងការណ៍ថា ៖ ខ្ញុំបាទសូមរក្សាខ្លឹមសារដូចមានក្នុងពាក្យបណ្តឹងចុះថ្ងៃទី១៣ ខែវិច្ឆិកាឆ្នាំ២០២០ទុកជាបានការដដែល ។ ខ្ញុំបាទសូមបញ្ជាក់បន្ថែមថា នៅថ្ងៃដែលខ្ញុំបាទបានចុះកិច្ចសន្យាទិញ-លក់ដីនិងផ្ទះរហូតមកដល់អំឡុងដើមខែមិថុនា ឆ្នាំ ២០១៩ ខ្ញុំបាទបានទទួលប្រាក់កក់សរុបចំនួន៤លើកដែលមានទឹកប្រាក់ចំនួនសរុប ៧៥០០០$ (ប្រាំពីរម៉ឺនប្រាំពាន់ដុល្លារអាមេរិក )

-ក្នុងការប្រគល់ប្រាក់ខាងលើ ពេលខ្លះខ្ញុំបាទបានទទួលប្រាក់តាមរយៈផ្ទាល់ដៃមិនបានសរសេរជាលាយលក្ខ័អក្សរទេ និងពេលខ្លះខ្ញុំបាទទទួលដោយមានឯកសារទទួលនិងប្រគល់ត្រឹមត្រូវ ។

-មូលហេតុបានជាខ្ញុំបាទបានទទួលប្រាក់ខាងលើ ពីចុងចម្លើយមិនតាមកាលបរិច្ឆេទកំណត់ដូចក្នុងកិច្ចសន្យាទិញ-លក់ដីនិងផ្ទះ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ត្រង់ចំណុចប្រកា ៤ ដែលភាគីចុង

ចម្លើយត្រូវបង់ប្រាក់ថ្លៃលក់ដីនិងផ្ទះ ដែលនៅសល់ចំនួនបង្គ្រប់ គឺដោយសារតែភាគីចុងចម្លើយបានអះអាងថាគាត់ពុំមានលទ្ធភាពនិងហើយគាត់សំណូមពរអោយខ្ញុំបាទ ផ្ទេកម្មសិទ្ធិអោយទៅភាគីចុងចម្លើយ ដើម្បីគាត់យកទៅដាក់បញ្ចាំនៅធនាគារ ដើម្បីយកប្រាក់មកបង់បង្គ្រប់អោយថ្លៃទិញដីនិងផ្ទះ ដោយមានធ្វើកិច្ចសន្យាខ្ចីប័ត្រកម្មសិទ្ធិ (ដី-ផ្ទះ )ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៩ ។

-នៅថ្ងៃទី១៣ ខែ មិថុនាឆ្នាំ ២០១៩ ជាថ្ងៃចុះកិច្ចសន្យាខ្ចីប័ត្រកម្មសិទ្ធិ (ដី-ផ្ទះ)ដែលចុងចម្លើយបានប្រគល់មូលប្បទានបត្រដែលមានលេខ៣៣៥៧១២មានទឹកប្រាក់ចំនួន៥០០០០$(ប្រាំម៉ឺនដុល្លារអាមេរិក )សំរាប់ឲ្យខ្ញុំបាទបើកប្រាក់នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១៩ នៅធនាគារវឌ្ឍនៈអាស៊ីចំកាត់។លុះដល់ពេលកំណត់ខ្ញុំបាទទៅបើកប្រាក់ខាងធនាគារបានបញ្ជាក់ប្រាប់ខ្ញុំថា ពុំមានសាច់ប្រាក់ទេ បន្ទាប់មកទៀតខ្ញុំបាទបានព្យាយាមទាក់ទងទៅគាត់តែទាក់ទងមិនបានរហូតមកដល់ពេលនេះ ។

-សេចក្តីថ្លែងការណ៍លោក **ខៀវ ចាន់** និងលោក **ម៉ែន លន់** ជាមេធាវី តំណាងដោយអាណត្តិឲ្យចុងចម្លើយជាភាគីខាងយើងខ្ញុំសុំច្រានចោលទាំងស្រុងរបស់ដើមចោទដូចមាននៅក្នុងពាក្យបណ្តឹងដោយមូលហេតុថា:

-កូនក្តីយើងខ្ញុំពុំមានចេតនាក្នុងការគេចវេសក្នុងការទទួលខុសត្រូវអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យានោះទេ ជាក់ស្តែងរហូតមកដល់ពេលនេះកូនក្តីយើងខ្ញុំបានបង់ជូនទៅភាគីដើមបណ្តឹងចំនួនទៅ៤ដង ដែលមានទឹកប្រាក់ស្មើនឹង៧៥០០០$ (ប្រាំពីរម៉ឺនប្រាំ ពាន់ដុល្លារអាមេរិក )រួចហើយ ការខកខានមិនបានបង់ប្រាក់តាមកាលបរិច្ឆេទតាមកិច្ចសន្យាកន្លងមកដោយសារបញ្ហាសេដ្ឋកិច្ចធ្លាក់ចុះជំងឺរាតត្បាតកូវីដ១៩ ដោយដាក់លក់ផ្ទះមួយកន្លែងអាជីវកម្មផ្សេងៗមិនដំណើរការ។ ចំពោះការទំនាក់ទំនងមិនបានគឺមិនត្រឹមត្រូវទេ ដោយហេតុថា កូនក្តីយើងខ្ញុំមានលំនៅដ្ឋាននៅជិតផ្ទះដើមបណ្តឹងអ្នកភូមិជាមួយគ្នា លើសពីនេះ ដើមបណ្តឹងបានដាក់ពាក្យបណ្តឹងពីរឿងព្រហ្មទណ្ឌមកសាលាដំបូងខេត្តកណ្តាលទាក់ទងទៅនឹងសែកអត់លុយកាលពីខែកញ្ញាឆ្នាំ២០២០កន្លងទៅ ។

<u>សំណូមពរៈ</u>

១-អនុញ្ញាតិឲ្យបញ្ចប់កិច្ចសន្យាទិញ-លក់ដីនិងផ្ទះ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ លុះត្រាតែភាគីដើមបណ្តឹងវេផ្ទេប្បវេណីបង្វិលប្រាក់កក់សរុបចំនួន៧៥០០០$(ប្រាំពីរម៉ឺនប្រាំពាន់ដុល្លារអាមេរិក) មកឲ្យកូនក្តីយើងខ្ញុំវិញ ។

២-សុំអនុញ្ញាតិឲ្យភាគីដើមបណ្តឹងទុកពេលវេលាឲ្យកូនក្តីយើងខ្ញុំស្វែងរកលទ្ធភាពសងដោយការលក់ផ្ទះមួយកន្លែងនៅភូមិតាក្តុល សង្កាត់តាក្តុល ក្រុងតាខ្មៅ ខេត្តកណ្តាល ។

ដើមបណ្តឹងបានធ្វើសេចក្តីថ្លែងការណ៍តបវិញថាៈខ្ញុំពុំយល់ព្រមតាមការអះអាងរបស់លោកមេធាវីតំណាងដោយអាណត្តិចុងចម្លើយដែលបានលើឡើងថា កូនក្តីរបស់គាត់មិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា គឺដោយសារជំងឺកូវីដរាតត្បាត ពុំមែនជាការពិតទេ ពីព្រោះការអនុវត្តតាមកាតព្វកិច្ចនេះគឺធ្វើមុនពេលបញ្ហាជំងឺកូវីដ១៩រាតត្បាតទៀត ។

ចំណុចវិវាទៈ សែកអត់លុយ និងមិនគោរពតាមកិច្ចសន្យាទិញ-លក់ដីនិងផ្ទះ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩។

ចំណុចគ្មានវិវាទៈទទួលស្គាល់ប្រាក់កក់ថ្លៃទិញ-លក់ដីនិងផ្ទះ សរុបចំនួន៧៥០០០$(ប្រាំពីរម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ។

តុលាការកំណត់ពេលឲ្យគូភាគីដាក់កស្តុតាងរយៈពេល៤សប្តាហ៍ និងកំណត់កាលបរិច្ឆេទនៅពេលក្រោយដើម្បីបន្តនីតិវិធីសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ។

បញ្ឈប់កំណត់ហេតុនៅវេលាម៉ោងដប់មួយកន្លះព្រឹក ថ្ងៃខែឆ្នាំដូចខាងលើ សរសេរចប់ យើងបានអានសេចក្តីទាំងស្រុងនៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នេះ ឲ្យសាមីខ្លួនស្តាប់ ហើយឆ្លើយថាត្រឹមត្រូវ និងសុខចិត្តផ្តិតម្រាមដៃជាមួយយើង។

ក្រឡាបញ្ជី | ចៅក្រម

ដើមចោទ | មេធាវីដើមចោទ | ចុងចម្លើយ | មេធាវីចុងចម្លើយ